អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍

**Action for Research and Development ‘ARD’**

# វគ្គស្ដីពីជំនាញគ្រូបណ្ដុះបណ្ដាល

# Training of Trainer ‘TOT’

ខែឧសភា ឆ្នាំ ២០០៧

អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍

**Action for Research and Development ‘ARD’**

# វគ្គស្តីពីជំនាញគ្រូបណ្តុះបណ្តាល

# Training of Trainer ‘TOT’


រៀបចំឡើងដោយ

កម្មវិធីពង្រឹងសមត្ថភាព ស្រាវជ្រាវ និងបោះពុម្ព

**Prepared by**

**Capacity Building, Research and Publication Program**

## មាតិកា


**សេចក្តីផ្តើមអំពីការអប់រំក្រៅប្រព័ន្ធ........................................................ ១**

ការអប់រំក្នុងប្រពន្ធ័........................................................................................ ១

ការអប់រំក្រៅប្រពន្ធ័........................................................................................ ១

ការអប់រំក្រៅផ្លូវការ ........................................................................................ ២

**ការប៉ាន់ប្រមាណតម្រូវការវគ្គបណ្តុះបណ្តាល............................................ ៣**

អ្វីទៅជាការប៉ាន់ប្រមាណតម្រូវការវគ្គបណ្តុះបណ្តាល?........................................................ ៣

ពាក្យគន្លឹះ ដើម្បីធ្វើការប៉ាន់ប្រមាណតម្រូវការវគ្គបណ្តុះបណ្តាល........................................... ៣

ហេតុអ្វីបានជាយើង ត្រូវធ្វើការប៉ាន់ប្រមាណពីតម្រូវការវគ្គបណ្តុះបណ្តាល?............................ ៤

តើត្រូវធ្វើការប៉ាន់ប្រមាណតម្រូវការវគ្គបណ្តុះបណ្តាល យ៉ាងដូចម្តេច?.................................... ៤

**ការរៀបចំបង្កើតវគ្គបណ្តុះបណ្តាល............................................................. ៦**

អំពីការរៀបចំគោលបំណងវគ្គ........................................................................ ៦

ប្រធានបទដែលត្រូវផ្តល់ក្នុងវគ្គបណ្តុះបណ្តាល ព្រមទាំងការរៀបចំឯកសារ និងគំរោងមេរៀន....... ៧

**ការរៀបចំគំរោងមេរៀន........................................................................ ៨**

អ្វីទៅជាគំរោងមេរៀន?.................................................................................. ៨

សារៈសំខាន់ នៃការរៀបចំគំរោងមេរៀន.......................................................... ៨

ចំណុចសំខាន់ៗដែលត្រូវបញ្ចូលទៅក្នុងគំរោងមេរៀន......................................... ៨

**វិធីសាស្ត្របណ្តុះបណ្តាល....................................................................... ១១**

ការបំផុសគំនិត............................................................................................ ១២

ការពិភាក្សាជាក្រុម...................................................................................... ១២

ការធ្វើបង្ហាញ............................................................................................. ១៤

ការសំដែងតួ................................................................................................ ១៤

ការសិក្សាករណី........................................................................................... ១៥

ការឧទ្ទេសនាម............................................................................................ ១៦

ទស្សនះកិច្ចសិក្សា........................................................................................ ១៧

ល្បែងពញ្ញាក់អារម្មណ៍.................................................................................. ១៧

**អំពីគ្រូបណ្តុះបណ្តាល.................................................................. ១៨**

តួនាទីសំខាន់ៗចំបងសំរាប់គ្រូបណ្តុះបណ្តាល.................................................................. ១៨

សមត្ថភាពដែលគ្រូបណ្តុះបណ្តាលត្រូវមាន.................................................................. ១៨

បញ្ហា និងវិធីសាស្ត្រដោះស្រាយសំរាប់គ្រូបណ្តុះបណ្តាល.................................................. ១៩

ការប្រើប្រាស់កាយវិការ និងអាកប្បកិរិយាសំរាប់គ្រូបណ្តុះបណ្តាល........................................ ២០

**ការរៀនសូត្ររបស់មនុស្សពេញវ័យ.................................................................. ២២**

ភាពខុសគ្នា នៃការរៀនរបស់កុមារ និងការរៀនរបស់មនុស្សចាស់........................................ ២២

វិធីសាស្ត្រដើម្បីជំរុញអោយសិក្ខាកាម/អ្នកភូមិមានការចូលរួម............................................ ២៤

លក្ខណៈសម្បត្តិរបស់សំរបសំរួល.................................................................. ២៥

លក្ខណៈសម្បត្តិដែលអ្នកសំរបសំរួលត្រូវជៀសវាង.................................................................. ២៦

**ការសំរបសំរួល.................................................................. ២៨**

និយមន័យការសំរបសំរួល.................................................................. ២៨

សារៈសំខាន់ នៃការសំរបសំរួល.................................................................. ៣០

**ជំនាញសំខាន់ៗ ដែលអ្នកសំរបសំរួលត្រូវមាន.................................................. ៣២**

ជំនាញក្នុងការសួរសំនួរ.................................................................. ៣២

ជំនាញក្នុងការស្តាប់.................................................................. ៣៤

ជំនាញធ្វើការបង្ហាញ.................................................................. ៣៦

ជំនាញក្នុងការប្រាស្រ័យទាក់ទង.................................................................. ៣៧

**ការវាយតំលៃវគ្គបណ្តុះបណ្តាល.................................................................. ៤០**

ប្រភេទនៃការវាយតំលៃ.................................................................. ៤០

ចំនុចដែលត្រូវធ្វើការវាយតំលៃ.................................................................. ៤០

ការវាយតំលៃមុនវគ្គបណ្តុះបណ្តាល.................................................................. ៤០

ការវាយតំលៃពេលកំពុងអនុវត្តវគ្គបណ្តុះបណ្តាល.................................................................. ៤១

ការវាយតំលៃពេលបញ្ចប់វគ្គបណ្តុះបណ្តាល.................................................................. ៤១

ការវាយតំលៃនៅក្រោយពេលបញ្ចប់វគ្គបណ្តុះបណ្តាល.................................................. ៤១

វិធីសាស្ត្រវាយតំលៃ.................................................................. ៤១

ពាក្យគន្លឹះនៅក្នុងការវាយតំលៃ.................................................................. ៤១

## **កាលវិភាគ**

## **វគ្គបណ្តុះបណ្តាល ស្តីពីជំនាញគ្រូបណ្តុះបណ្តាល**

| **ម៉ោង** | **ប្រធានបទ** | **វិធីសាស្ត្រ** | **សំភារៈ** |
|---|---|---|---|
| **ថ្ងៃទី១ ( រយៈពេល ៤ ម៉ោង)** | | | |
| ០៨:០០-០៨:៣០ | ការណែនាំអោយស្គាល់គ្នា | ល្បែងចាប់គូ | |
| ០៨:៣០-០៩:០០ | បទបញ្ជាផ្ទៃក្នុងរបស់វគ្គ | បំផុសគំនិត | ហ្វឺត,ក្រដាសផ្ទាំងធំ |
| ០៩:០០-០៩:៣០ | ការបោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានវគ្គ | បោះឆ្នោតសំងាត់ | សន្លឹកឆ្នោត,<br>ធុងឆ្នោត |
| ០៩:៣០-១០:០០ | សំរាក | | |
| ១០:០០-១១:០០ | គោលបំណង និងលទ្ធផលរពឹងទុករបស់សិក្ខាកាម | ល្បែងគំនិតខ្ញុំ | ក្រដាសផ្ទាំងធំ, ហ្វឺត |
| ១១:០០-១២:០០ | សំណួរសាកល្បងមុនពេលចាប់ផ្តើមវគ្គ<br>កាលវិភាគសំរាប់វគ្គបណ្តុះបណ្តាលជំនាញគ្រូបង្គោល | ឆ្លើយសំណួរ | បញ្ជីសំណួរ |
| **ថ្ងៃទី២ ( រយៈពេល ៤ ម៉ោង)** | | | |
| ០៧:៣០-០៨:០០ | សេចក្តីផ្តើមស្តីពីការអប់រំក្រៅប្រព័ន្ធ | | |
| ០៨:០០-០៩:៣០ | ការប៉ាន់ប្រមាណតំរូវការវគ្គបណ្តុះបណ្តាល | | |
| ០៩:៣០-១០:០០ | សំរាក និងល្បែងថាមពល | | |
| ១០:០០-១១:៣០ | ការរៀបចំបង្កើតវគ្គបណ្តុះបណ្តាល<br>ការរៀបចំគោលបំណងវគ្គ | | |
| **ថ្ងៃទី ៣ ( រយៈពេល ៤ ម៉ោង)** | | | |
| ០៧:៣០-០៨:០០ | រំលឹកមេរៀន | | |
| ០៨:០០-០៩:៣០ | ការរៀបចំគំរោងមេរៀន | | |
| ០៩:៣០-១០:០០ | សំរាក និងល្បែងថាមពល | | |
| ១០:០០-១១:៣០ | លំហាត់ស្តីពីការរៀបចំគំរោងមេរៀន | | |
| **ថ្ងៃទី៤ ( រយៈពេល ៤ម៉ោង)** | | | |
| ០៧:៣០-០៨:០០ | រំលឹកមេរៀន | | |
| ០៨:០០-០៩:៣០ | វិធីសាស្ត្របណ្តុះបណ្តាល | | |

| | | | |
|---|---|---|---|
| ០៩:៣០-១០:០០ | សំរាក និងល្បែងថាមពល | | |
| ១០:០០-១១:៣០ | វិធីសាស្រ្តបណ្តុះបណ្តាល | | |
| **ថ្ងៃទី ៥ (រយៈពេល ៤ ម៉ោង)** | | | |
| ០៧:៣០-០៩:៣០ | លំហាត់ជាក់ស្តែងពីវិធីសាស្រ្តបណ្តុះបណ្តាល | | |
| ០៩:៣០-១០:០០ | សំរាក និងល្បែងថាមពល | | |
| ១០:០០-១១:៣០ | អំពីគ្រូបណ្តុះបណ្តាល | | |
| **ថ្ងៃទី ៦ (រយៈពេល ៤ម៉ោង)** | | | |
| ០៧:៣០-០៨:០ | រំលឹកមេរៀន | | |
| ០៨:០០-០៩:៣០ | ការរៀនសូត្ររបស់មនុស្សពេញវ័យ | | |
| ០៩:៣០-១០:០០ | សំរាក និងល្បែងថាមពល | | |
| ១០:០០-១១:៣០ | ការសំរបសំរួល | | |
| **ថ្ងៃទី ៧ (រយៈពេល ៤ម៉ោង)** | | | |
| ០៧:៣០-០៨:០០ | រំលឹកមេរៀន | | |
| ០៨:០០-០៩:៣០ | ជំនាញសំខាន់ៗដែលអ្នកសំរបសំរួលត្រូវមាន | | |
| ០៩:៣០-១០:០០ | សំរាក និងល្បែងថាមពល | | |
| ១០:០០-១១:៣០ | ជំនាញសំខាន់ៗដែលអ្នកសំរបសំរួលត្រូវមាន | | |
| **ថ្ងៃទី ៨ (រយៈពេល ៤ម៉ោង)** | | | |
| ០៧:៣០-០៨:០០ | រំលឹកមេរៀន | | |
| ០៨:០០-០៩:៣០ | ការវាយតំលៃវគ្គបណ្តុះបណ្តាល | | |
| ០៩:៣០-១០:០០ | សំរាក និងល្បែងថាមពល | | |
| ១០:០០-១០:៤៥ | ការវាយតំលៃវគ្គបណ្តុះបណ្តាល | | |
| ១០:៤៥-១១:៣០ | សំណួរសាកល្បងពេលបញ្ចប់វគ្គបណ្តុះបណ្តាល | | |

☛ **យើងខ្ញុំសូមរក្សាសិទ្ធិក្នុងការកែប្រែកម្មវិធីបណ្តុះបណ្តាលក្នុងករណីចាំបាច់!!!**

**សូមអរគុណ!!!**

# សេចក្តីផ្តើមអំពីការអប់រំក្រៅប្រព័ន្ធ
# Introduction of Non-Formal Education

ការអប់រំ ត្រូវបានគេចែកជា៣ប្រភេទសំខាន់ គឺ ការអប់រំក្នុងប្រព័ន្ធ (Formal Education), ការអប់រំក្រៅប្រព័ន្ធ (Non-Formal Education), និងការអប់រំក្រៅផ្លូវការណ៏ (Informal Education) ។

## ១. ការអប់រំក្នុងប្រព័ន្ធ (Formal Education)

ការអប់រំក្នុងប្រព័ន្ធ គឺជាការអប់រំមួយបែប ដែលប្រព្រឹត្តិទៅនៅក្នុងការបង្កើតជាផ្លូវការណ៏ ដូចជា សាលារៀន, មហាវិទ្យាល័យ, សាលាបច្ចេកទេស ។

តើការអប់រំក្នុងប្រព័ន្ធមានលក្ខណៈយ៉ាងដូចម្តេច?

- បង្រៀនមុខវិជ្ជា
- អនាគតត្រូវបានគេតំរង់ទិស
- អ្វីដែលគេត្រូវរៀន ត្រូវបានសំរេចដោយរាជរដ្ឋាភិបាល រឺអ្នកជំនាញការដទៃទៀត
- មានគ្រូ និងមានសិស្ស
- សិស្សបញ្ចេញយោបល់តិច
- មានការឃ្លាតឆ្ងាយរវាងគ្រូ និងសិស្ស
- មានវិន័យតឹងតែង

## ២. ការអប់រំក្រៅប្រព័ន្ធ (Non-Formal Education)

ការអប់រំក្រៅប្រព័ន្ធ គឺជាការអប់រំមួយបែប ដែលប្រព្រឹត្តិទៅនៅក្រៅសាលារៀន រឺវិទ្យាស្ថានបណ្តុះបណ្តាល ដូចជា អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៏ ធ្វើការបណ្តុះបណ្តាលវគ្គខ្លីៗដល់និស្សិត បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល និងសហគមន៏ ជាដើម ។

តើការអប់រំក្នុងប្រព័ន្ធមានលក្ខណៈយ៉ាងដូចម្តេច?

- រៀបចំអោយក្រុមគោលដៅរបស់ខ្លួន អោយពង្រីកសមត្ថភាព និងធ្វើការងាររបស់ពួកគេអោយបានកាន់តែប្រសើរ
- ជួយពង្រីកជំនាញដែលពួកគេត្រូវការជាបន្ទាន់ក្នុងការរស់នៅ
- មិនបានបង្រៀនមុខវិជ្ជា
- បង្រៀនអ្នកសិក្សាអោយសម្រេចការងារ ដែលគេបានជួបប្រទះក្នុងជីវិត
- អ្នកចូលរួមសិក្សាជាអ្នកធ្វើការសំរេចចិត្តលើកម្មវិធី ។ ពួកគេអាចរៀនអ្វីដែលពួកគេអាចយកទៅប្រើប្រាស់បានភ្លាមៗ ។
- រៀនដោះស្រាយបញ្ហា

ការអប់រំក្រៅប្រព័ន្ធ បានផ្តល់វិភាគទានយ៉ាងច្រើន នៅប្រទេសកម្ពុជាយើង ខណៈដែលការអប់រំក្នុងប្រព័ន្ធនៅមាន

លក្ខណៈទន់ខ្សោយ វាមិនត្រូវបានគេរៀបចំ វាត្រូវបានរំខានដោយអស្ថេរភាពនយោបាយ ។

## ៣. ការអប់រំក្រៅផ្លូវការណ៍ (Informal Education)

ការអប់រំក្រៅផ្លូវការណ៍ គឺជាការអប់រំមួយបែប ដែលកើតឡើងដោយគ្មានការប្រឹងប្រែងជាពិសេសនោះទេ ដោយគ្រប់រូបអាចរៀនសូត្របានតាមរយៈការរស់នៅប្រចាំថ្ងៃ ។

# ការប៉ាន់ប្រមាណតម្រូវការវគ្គបណ្តុះបណ្តាល
# Training Need Assessment

## ១. អ្វីទៅជាការប៉ាន់ប្រមាណតម្រូវការវគ្គបណ្តុះបណ្តាល?

### តម្រូវការ ជាអ្វី?

- តម្រូវការ គឺជាបំណងប្រាថ្នា គឺជាចំណង់ចំណូលចិត្តរបស់បុគ្គលនីមួយៗ

### ការប៉ាន់ប្រមាណតម្រូវការ ជាអ្វី?

- ការប៉ាន់ប្រមាណតម្រូវការ គឺជាកំណត់រកនូវតម្រូវការរបស់បុគ្គល រឺក្រុមគោលដៅមួយ

តាមរយៈការបង្ហាញនូវអត្ថន័យតម្រូវការ និងការប៉ានប្រមាណតម្រូវការ ខាងលើ យើងអាចអោយអត្ថន័យ នៃការប៉ាន់ប្រមាណតម្រូវការវគ្គបណ្តុះបណ្តាល ថាជាការកំណត់នូវតម្រូវការប្រធានបទ សំរាប់ធ្វើការបណ្តុះបណ្តាលដល់ក្រុមគោលដៅដែលជាសិក្ខាកាមរបស់វគ្គបណ្តុះបណ្តាលមួយ ។

ការប៉ាន់ប្រមាណតម្រូវការ ដែលមានការចូលរួមពីសិក្ខាកាម រឺសហគមន៍ វានឹងជំរុញអោយក្រុមគោលដៅរបស់យើង "សិក្ខាកាម" មានការខិតខំប្រឹងប្រែងនៅក្នុងការទទួលយកនូវចំណេះដឹង បទពិសោធន៍ដែលយើងបានផ្តល់អោយ និងធ្វើអោយពួកគេមានអារម្មណ៏ថាពួកគេគឺជាម្ចាស់ នៅក្នុងវគ្គបណ្តុះបណ្តាលនេះ ។ ម្យ៉ាងវិញទៀតការប៉ាន់ប្រមាណតម្រូវការ វានឹងជួយធ្វើអោយមានសន្ទស្សន៍សម្រាប់ធ្វើការវាយតំលៃលើវគ្គបណ្តុះបណ្តាលផងដែរ ។

ដើម្បីអោយវគ្គបណ្តុះបណ្តាលមានទំនាក់ទំនងគនា មានផលប្រយោជន- និងសំរេចជោគជ័យ វគ្គបណ្តុះបណ្តាលនោះ គួរតែបំពេញបំណងចំពោះសេចក្តីត្រូវការរបស់សហគមន៍ រឺសិក្ខាកាម ។ វគ្គបណ្តុះបណ្តាលទាមទារពត៌មានដែលអាចប្រើប្រាស់ និងជឿទុកចិត្តបាន និងត្រឹមត្រូវ ហើយឆ្លុះបញ្ចាំងទៅនឹងសេចក្តីត្រូវការរបស់វគ្គបណ្តុះបណ្តាល ។ គ្រូបណ្តុះបណ្តាលមិនត្រូវស្មានទាំងស្រុងទៅលើ រឺកំណត់ប្រធានបទដោយមិនស្របទៅតាមអ្វីដែលសិក្ខាកាមចង់បាននោះឡើយ ។

## ២. ពាក្យគន្លឹះ ដើម្បីធ្វើការប៉ាន់ប្រមាណតម្រូវការវគ្គបណ្តុះបណ្តាល

ដើម្បីធ្វើការប៉ាន់ប្រមាណតម្រូវការវគ្គបណ្តុះបណ្តាល ត្រូវចងចាំនូវពាក្យគន្លឹះមួយឃ្លាថា "អ្នកណាត្រូវការអ្វី ហើយអ្វីនោះត្រូវផ្តល់ដោយអ្នកណា?"

**អ្នកណា "ទី១ " :** គឺសំដៅទៅលើប្រភេទមនុស្សដែលត្រូវចូលរួមជាសិក្ខាកាមនៅក្នុងវគ្គបណ្តុះបណ្តាល ។ ឧទាហរណ៍ សិក្ខាកាមជា និស្សិត រឺជាបុគ្គលិកអង្គការ រឺជាកសិករ ។ល ។

**អ្វីទាំងនោះ :** គឺសំដៅទៅលើប្រភេទតម្រូវការរបស់សិក្ខាកាម ។ អ្វីទាំងនោះ គឺជាប្រធានបទ ដែលនឹងនាំទៅអោយសំរេចគោលបំណងរបស់សិក្ខាកាមនៅក្រោយពេលបញ្ចប់វគ្គបណ្តុះបណ្តាល ។

**អ្នកណា "ទី២ "** : គឺសំដៅទៅលើប្រភេទមនុស្ស ដែលអាចមានសមត្ថភាពគ្រប់គ្រាន់ និងសមស្រប សំរាប់ផ្តល់នូវអ្វីៗទាំងឡាយដែលជាតម្រូវការរបស់សិក្ខាកាម។ និយាយរួម គឺសំដៅទៅលើ គ្រូបណ្តុះបណ្តាល ដែលនឹងចូលរួមសំរបសំរួលនៅក្នុងវគ្គបណ្តុះបណ្តាលនោះ។

## ៣. ហេតុអ្វីបានជាយើង ត្រូវធ្វើការប៉ាន់ប្រម៉ាណពីតម្រូវការវគ្គបណ្តុះបណ្តាល?

ការធ្វើការប៉ាន់ប្រមាណពីតម្រូវការវគ្គបណ្តុះបណ្តាល ចាំបាច់ត្រូវធ្វើឡើងដើម្បី :

- រកនូវអ្វីដែលអ្នកសិក្សាត្រូវការចាំបាច់ និងអ្វីដែលគេចេះដឹងរួចហើយ
- រៀបចំវគ្គសិក្សាអោយត្រូវនឹងតម្រូវការរបស់អ្នកសិក្សា ហើយនិងរៀបចំមេរៀនអោយត្រូវនឹងចំណេះដឹង ការងាររបស់ពួកគេ
- ប្រមូលពត៌មាន ដើម្បីរៀបចំគោលដៅ និងគោលបំណងរបស់វគ្គបណ្តុះបណ្តាល
- ធ្វើអោយកម្មវិធីសិក្សាផ្តោតការយកចិត្តទុកដាក់ចំពោះអ្នកចូលរួម

## ៤. តើត្រូវធ្វើការប៉ាន់ប្រមាណតម្រូវការវគ្គបណ្តុះបណ្តាល យ៉ាងដូចម្តេច?

មានវិធីសាស្ត្រជាច្រើន ដែលអាចធ្វើការប៉ាន់ប្រមាណពីតម្រូវការវគ្គបណ្តុះបណ្តាល ដូចជា :

- ការសួរសំណួរបំផុសគំនិត
- ការសំភាសន៍
- ការប្រជុំពិភាក្សាជាក្រុម
- ការប្រើប្រាស់បញ្ជីសំណួរ

នៅក្រោយពីការប្រើប្រាស់វិធីសាស្ត្រខាងលើនេះរួចហើយ យើងត្រូវធ្វើការវិភាគលើពត៌មានដែលទទួលបានទាំងនោះ ដើម្បី:

- កំណត់រកអោយឃើញនូវតម្រូវការ
- រៀបចំអាទិភាពតម្រូវការ

☛ នៅក្នុងការប៉ាន់ប្រមាណតម្រូវការបណ្តុះបណ្តាល យើងត្រូវកំណត់ជាចំបងថា តើសិក្ខាកាមមានកំរិតយល់ដឹងកំរិតណាលើការងាររបស់ពួកគេ និងថាតើពួកគេចង់រៀនពីអ្វីខ្លះ?

### ឧទាហរណ៍គំរូពីការប៉ាន់ប្រមាណតម្រូវការវគ្គបណ្តុះបណ្តាល

**១.ទិន្នន័យបុគ្គល:** ឈ្មោះ............................................ភេទ..........ថ្ងៃខែឆ្នាំកំណើត..................................................

ទីកន្លែងកំណើត..........................................................................................................................................

ទីលំនៅបច្ចុប្បន្ន.........................................................................................................................................

ទូរស័ព្ទ និងអ៊ីម៉ែលសំរាប់ទាក់ទង.............................................................................................................

មុខរបរ (បញ្ជាក់ពីមុខតំណែង, ផ្នែក និងឈ្មោះស្ថាប័ន, រឺបើជានិស្សិត បញ្ជាក់ពីមុខជំនាញដែលកំពុងសិក្សា, ឈ្មោះមហាវិទ្យាល័យ):.................................................................................................................................

.................................................................................................................................................

.................................................................................................................................................

២. តើអ្នកធ្លាប់បានចូលរៀនវគ្គបណ្តុះបណ្តាលអ្វីខ្លះពីពេលមុនកន្លងមក?

ក. ឈ្មោះវគ្គ................................................................., ស្ថាប័នបណ្តុះបណ្តាល.......................................

ខ. ឈ្មោះវគ្គ................................................................., ស្ថាប័នបណ្តុះបណ្តាល.......................................

គ. ឈ្មោះវគ្គ................................................................., ស្ថាប័នបណ្តុះបណ្តាល.......................................

ឃ. ឈ្មោះវគ្គ................................................................., ស្ថាប័នបណ្តុះបណ្តាល.......................................

ង. ឈ្មោះវគ្គ................................................................., ស្ថាប័នបណ្តុះបណ្តាល.......................................

៣. តើអ្នកគិតថា ជំនាញអ្វីខ្លះដែលអ្នកគួរពង្រឹងបន្ថែម ដើម្បីជួយបង្កើននូវចំណេះដឹង បទពិសេធន៍ និងប្រសិទ្ធិភាពការងារ រឺការសិក្សារបស់អ្នក?..........................................................................................................................

.................................................................................................................................................

.................................................................................................................................................

៤. ប្រសិនបើមានវគ្គបណ្តុះបណ្តាល ត្រូវបានរៀបចំដូចខាងក្រោមនេះ តើអ្នកនឹងជ្រើសរើសវគ្គណាមួយដើម្បីចូលរួមរៀនក្នុងវគ្គបណ្តុះបណ្តាលនេះ?

☐ ការគ្រប់គ្រងគំរោង ☐ ជំនាញសំរបសំរួល

☐ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ☐ ការងារអភិវឌ្ឍន៍សហគមន៍

☐ ជំនាញគ្រូបណ្តុះបណ្តាល ☐ ការអភិវឌ្ឍន៍អាជីពការងារ

☐ ការវាយតំលៃជនបទដោយមានការចូលរួម ☐ ការត្រួតពិនិត្យ និងវាយតំលៃគំរោង

☐ ការធ្វើការងារជាក្រុម ☐ ការគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាព

☐ វិធីសាស្ត្រស្រាវជ្រាវ និងសរសេររបាយការណ៍ ☐ ការចងក្រងក្រុម រឺសហគមន៍កសិករ

៥. ក្រៅពីវគ្គបណ្តុះបណ្តាល ដែលបង្ហាញនៅក្នុងសំនួរទី៤ខាងលើ, តើអ្នកគិតថាមានវគ្គបណ្តុះបណ្តាលអ្វីទៀត ដែលសំខាន់សំរាប់អ្នក ដើម្បីកែលំអចំណេះដឹង និងបទពិសោធន៍របស់អ្នក?...................................................................................

.................................................................................................................................................

.................................................................................................................................................

**សូមអរគុណ ចំពោះចំលើយរបស់លោក-អ្នក !!!**

# ការរៀបចំបង្កើតវគ្គបណ្តុះបណ្តាល
# Preparation for Training Conduction

ដើម្បីបង្កើតវគ្គបណ្តុះបណ្តាលមួយ យើងត្រូវការរៀបចំ និងសំរេចចិត្តទៅលើចំនុចសំខាន់ៗ ដូចតទៅ :

- គោលបំណងរបស់វគ្គបណ្តុះបណ្តាល
- ប្រធានបទដែលត្រូវផ្តល់ក្នុងវគ្គបណ្តុះបណ្តាល ព្រមទាំងការរៀបចំឯកសារនិង គំរោងមេរៀន
- វិធីសាស្ត្រ និងសំភារៈសំរាប់ប្រើប្រាស់ក្នុងវគ្គបណ្តុះបណ្តាល
- ពេលវេលា និងទីកន្លែងដែលត្រូវបណ្តុះបណ្តាល

## ១. អំពីការរៀបចំគោលបំណងវគ្គ

ដើម្បីរៀបចំគោលបំណងសំរាប់វគ្គបណ្តុះបណ្តាល យើងត្រូវដឹងថា តើជាការបណ្តុះបណ្តាលសំរាប់អ្នកណា? និងបណ្តុះបណ្តាលអំពីអ្វី?

ការសរសេរគោលបំណងវគ្គបណ្តុះបណ្តាល ដែលមានលក្ខណៈល្អ គឺត្រូវសរសេរអោយមានលក្ខណៈ SMART គឺវាត្រូវមានលក្ខណៈ**ជាក់លាក់, អាចវាស់វែងបាន, អាចសំរេចបាន, ប្រាកដនិយម និងទាន់ពេលកំណត់**។

ពាក្យដែលមានន័យអាចវាស់វែងបាន ហើយសមស្របសំរាប់ប្រើប្រាស់នៅក្នុងការសរសេរគោលបំណងវគ្គបណ្តុះបណ្តាលមាន :

- **សរសេរ :** សិក្ខាកាមនឹងសរសេរពីគោលបំណងរបស់ខ្លួននៅក្នុងការចូលរួមវគ្គបណ្តុះបណ្តាលនេះ
- **រក :** សិក្ខាកាមនឹងរកឃើញនូវចំនុចសំខាន់ៗដើម្បីសរសេរពីគំរោងមេរៀន
- **ជ្រើសរើស :** សិក្ខាកាមនឹងជ្រើសរើសវិធីសាស្ត្រមួយមកអនុវត្តក្នុងការបណ្តុះបណ្តាលសាកល្បង
- **អោយនិយមន័យ :** សិក្ខាកាមអាចអោយនិយមន័យស្តីពីអ្វីទៅជាការប៉ាន់ប្រមាណតំរូវការវគ្គបណ្តុះបណ្តាល
- **អនុវត្តន៍ :** សិក្ខាកាមនឹងអនុវត្តសរសេរគំរោងមេរៀន
- **ពិពណ៌នា :** សិក្ខាកាមនឹងពិពណ៌នាពីចំនុចសំខាន់ៗ ដើម្បីធ្វើការប៉ាន់ប្រមាណពីតំរូវការវគ្គបណ្តុះបណ្តាល
- **យក :** សិក្ខាកាមនឹងយកសំភារៈមកធ្វើការបង្ហាញតាមលំដាប់លំដោយ
- **ពិភាក្សា :** សិក្ខាកាមនឹងពិភាក្សាពីចំនុចខ្វះខាតរបស់វគ្គបណ្តុះបណ្តាល
- **ធ្វើបង្ហាញ :** សិក្ខាកាមនឹងធ្វើបង្ហាញពីការចាក់វ៉ាក់សាំងការពារជំងឺសត្វ
- **ធ្វើ :** សិក្ខាកាមធ្វើការសំរបសំរួលសាកល្បងនៅក្នុងវគ្គបណ្តុះបណ្តាល

ពាក្យដែលមានន័យទំលូទំលាយមិនអាចធ្វើការវាស់វែងបាន ហើយដែលគួរជៀសវាងកុំប្រើប្រាស់នៅក្នុងការសរសេរគោលបំណងវគ្គបណ្តុះបណ្តាល :

- **យល់ :** សិក្ខាកាមនឹងយល់បានពីវិធីសាស្ត្រសំរបសំរួល

- **ដឹង :** សិក្ខាកាមនឹងដឹងអំពីរបៀបសរសេរគោលបំណងវគ្គបណ្តុះបណ្តាល
- **ស្គាល់ :** សិក្ខាកាមនឹងស្គាល់ពីរបៀបនៃការប៉ាន់ប្រមាណតម្រូវការវគ្គបណ្តុះបណ្តាល

☛ ***ឧទាហរណ៍ការសេរសេរគោលបំណងវគ្គបណ្តុះបណ្តាល :***

**គោលដៅ :**

ផ្តល់នូវចំណេះដឹង បទពិសោធន៍ ជំនាញ និងអាកប្បកិរិយា ដល់សិក្ខាកាមសរុបចំនួន ៣០នាក់ ដែលមកពីមហាវិទ្យាល័យនានាក្នុងព្រះរាជាណាចក្រកម្ពុជា និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដើម្បីអោយសិក្ខាកាមទាំងអស់ក្លាយជាគ្រូបណ្តុះបណ្តាលបន្តប្រកបដោយសមត្ថភាព ជំនាញ ។

**គោលបំណងជាក់លាក់ :**

នៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល ដែលមានរយៈពេល៣២ម៉ោងនេះ សិក្ខាកាមទាំងអស់នឹងបាន :

- សិក្សាពីអត្ថន័យនៃការប៉ាន់ប្រមាណពីតម្រូវការវគ្គបណ្តុះបណ្តាល
- សិក្សាពីវិធីសាស្ត្រនៃការបណ្តុះបណ្តាលដែលប្រកបដោយប្រសិទ្ធិភាព និងបានអនុវត្តជាក់ស្តែងនៅក្នុងការសំរបសំរួលសាកល្បងនៅក្នុងវគ្គបណ្តុះបណ្តាល ។

## ២. ប្រធានបទដែលត្រូវផ្តល់ក្នុងវគ្គបណ្តុះបណ្តាល ព្រមទាំងការរៀបចំឯកសារ និងគំរោងមេរៀន

ប្រធានបទដែលត្រូវសំរបសំរួលក្នុងវគ្គបណ្តុះបណ្តាល ត្រូវបានជ្រើសរើស និងរៀបចំនៅក្រោយពីការប៉ាន់ប្រមាណតម្រូវការវគ្គបណ្តុះបណ្តាល ត្រូវបានបញ្ចប់ ។

ក្រោយពីប្រធានបទត្រូវបានកំណត់ និងជ្រើសរើសហើយ ការរៀបចំឯកសារមេរៀន និងគំរោងមេរៀនត្រូវបានចាប់ផ្តើម និងបញ្ចប់នៅមុនពេលដែលវគ្គបណ្តុះបណ្តាលដំណើរការ ។

# ការរៀបចំគំរោងមេរៀន
# Lesson Plan Preparation

## ១. អ្វីទៅជាគំរោងមេរៀន ?

គំរោងមេរៀន គឺជាប្លង់មេរៀនដែលរួមបញ្ចូលនូវចំនុចសំខាន់ៗ ដើម្បីជួយអោយអោយអ្នកសំរបសំរួល ដឹងនូវអ្វីដែលត្រូវបណ្តុះបណ្តាល ដោយបញ្ជាក់ពីលំដាប់លំដោយដែលត្រូវបណ្តុះបណ្តាល រួមជាមួយនឹងវិធីសាស្ត្របណ្តុះបណ្តាល សំភារៈ ព្រមទាំងពេលវេលាជាក់លាក់សំរាប់ការបណ្តុះបណ្តាល ។

## ២. សារៈសំខាន់ នៃការរៀបចំគំរោងមេរៀន

ការរៀបចំគំរោងមេរៀន មានសារៈសំខាន់ដើម្បីអោយអ្នកសំរបសំរួលដឹងនូវចំនុចសំខាន់ៗ និងជំហានដែលត្រូវបណ្តុះបណ្តាលទៅតាមលំដាប់លំដោយរបស់វា ព្រមទាំងត្រៀមជាមុននូវវិធិសាស្ត្រ សំភារៈ ដែលត្រូវអនុវត្តប្រើប្រាស់នៅក្នុងពេលបណ្តុះបណ្តាល ។

## ៣. ចំនុចសំខាន់ៗដែលត្រូវបញ្ចូលនៅក្នុងគំរោងមេរៀន

- **ប្រធានបទបណ្តុះបណ្តាល :** តើប្រធានបទ ដែលត្រូវលើកយកមកបណ្តុះបណ្តាលក្នុងពេលនេះ
- **គោលបំណងបណ្តុះបណ្តាល :** ត្រូវកំនត់អោយបានច្បាស់លាស់ ថាតើក្រោយពីបញ្ចប់វគ្គបណ្តុះបណ្តាលនេះ សិក្ខាកាមនឹងទទួលបានការយល់ដឹងពីអ្វីខ្លះ? គោលបណងត្រូវរៀបចំអោយមានលក្ខណៈច្បាស់លាស់ និងអាចវាស់វែងបាន ។
- **អ្នកសំរបសំរួល :** តើអ្នកណាដែលត្រូវសំរបសំរួលក្នុងពេលបណ្តុះបណ្តាលប្រធានបទនេះ?
- **អ្នកចូលរួម :** បញ្ជាក់ប្រាប់អំពីប្រភេទ និងចំនួនសិក្ខាកាមដែលត្រូវចូលរួម
- **ទីកន្លែង :** តើការបណ្តុះបណ្តាលនេះប្រព្រឹត្តទៅនៅឯណា?
- **ពេលវេលា :** ប្រធានបទដែលលើកយកមកបណ្តុះបណ្តាល ត្រូវមានរយៈពេលប៉ុន្មាន?
- **វិធីសាស្ត្រ :** តើវិធីសាស្ត្រអ្វីខ្លះដែលត្រូវយកមកប្រើប្រាស់?
- **សំភារៈ :** តើសំភារៈអ្វីដែលត្រូវយកមកប្រើប្រាស់ក្នុងពេលបណ្តុះបណ្តាលនេះ?
- **ជំហាន/សកម្មភាព :** រៀបរាប់ពីសកម្មភាពសំខាន់ៗដែលត្រូវធ្វើក្នុងកំឡុងពេលបណ្តុះបណ្តាល ទៅតាមជំហានជាលំដាប់លំដោយនៃប្រធានបទ ។

### ឧទាហរណ៍គំរូក្នុងការរៀបចំគំរោងមេរៀន

| គំរោងមេរៀន ស្តីពីការសំរបសំរួល | |
|---|---|
| **គោលបំណង** | នៅទីបញ្ចប់នៃមេរៀននេះ សិក្ខាកាមទាំងអស់នឹង :<br>❑ យល់ច្បាស់ពីអត្ថន័យអំពីការសំរបសំរួល ។<br>❑ អាចអនុវត្តវិធីសាស្ត្រសំរបសំរួលដែលប្រកបដោយប្រសិទ្ធិភាព ។ |

## គំរោងមេរៀន ស្តីពីការសំរបសំរួល

**អ្នកសំរបសំរួល** លោក សួន សុខេង ( នាយកអង្គការ ARD)

**អ្នកចូលរួម** សិក្ខាកាមជាបុគ្គលិកមកពីបណ្តាអង្គការនានា និងនិស្សិតពីបណ្តាមហាវិទ្យាល័យផ្សេងៗ

**ទីកន្លែង** ការិយាល័យអង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៏ ARD

**រយៈពេល** ២ ម៉ោង ( ១០:០០-១២:០០)

**វិធីសាស្រ្ត** បំផុសគំនិត, លេងល្បែង, ការពិភាក្សាជាក្រុម

**សំភារៈ**

១. ក្រដាស់សផ្ទាំងធំ ។

២. ពង្រីកក្រដាសលំហាត់ បង្អួចចូហារី (Johari’s window) ។

**ជំហាន**

១. បែងចែកសិក្ខាកាមជាក្រុមដែលមានសមាជិកពី២-៤ នាក់ ។ ផ្តល់ដល់ក្រុមនីមួយៗនូវបង្អួចចូហារី ថតចំលងពង្រីក ( សូមមើលឯកសារចែកជូន) ។

២. ពន្យល់ : បង្អួចចូហារីបង្ហាញពីស្ថានភាព៤ផ្សេងៗគ្នា ដែលការសំរបសំរួលបានកើតមានឡើង ។ នៅក្នុងរូបភាពមានបុរសម្នាក់តំណាងអោយអ្នកសំរបសំរួល ហើយស្រ្តីម្នាក់តំណាងអោយអ្នកភូមិ ។ ស្នើអោយក្រុមនីមួយៗនោះបង្កើតជារឿងមួយ សំរាប់រូបភាពនីមួយៗ ។ ពួកគេត្រូវតែដាក់ពាក្យសន្ទនាចូលទៅក្នុងប្រអប់រូបភាពទាំងអស់នោះ ។ ផ្តល់ពេលវេលាអោយបានគ្រប់គ្រាន់សំរាប់ការបំផុសគំនិត និងការពិភាក្សា ។ លទ្ធផលដែលបានមកពីការពិភាក្សាត្រូវបន្ទាប់មកបង្ហាញដល់អ្នកចូលរួមទាំងអស់នៅក្នុងវគ្គ ។

៣. បន្ទាប់ពីការឡើងរាយការណ៍លទ្ធផលរបស់ក្រុម អ្នកសំរបសំរួល ដឹកនាំការពិភាក្សាមួយអំពីការសំរបសំរួល សួរដេញរកគំនិតរបស់សិក្ខាកាមអំពីអត្ថន័យនៃពាក្យដូចម្តេចដែលហៅថាការសំរបសំរួល ។ អ្នកសំរបសំរួលត្រូវការពន្យល់អំពីការសំរបសំរួលនោះថាគឺជាអត្ថន័យដ៏ទូលំទូលាយមួយ ប៉ុន្តែជាទូទៅគេអាចយល់បានថា ” ជាអ្វីមួយ ដែលនឹងធ្វើអោយអ្វីមួយផ្សេងៗទៀត មានលក្ខណៈងាយយល់” ។

៤. ជាគោលការណ៏ណែនាំ អ្នកសំរបសំរួលជំរុញអោយមានការពិភាក្សាមួយដែលអាននាំឈានទៅកំនត់បាននូវលក្ខណៈសម្បត្តិនៃអ្នកសំរបសំរួលល្អដូចខាងក្រោម :

- ស្តាប់រឿងរ៉ាវរបស់សិក្ខាកាម/អ្នកភូមិ។
- ជំរុញសិក្ខាកាម/អ្នកភូមិអោយហ៊ានទិយាយ និងហ៊ានបង្ហាញអំពីទស្សនៈផ្ទាល់ខ្លួនរបស់ពួកគេ។
- ជំរុញអោយមានការចូលរួមពីសិក្ខាកាម/អ្នកភូមិ នៅក្នុងគ្រប់សកម្មភាព។

| គំរោងមេរៀន ស្តីពីការសំរបសំរួល | |
|---|---|
| កំណត់សំគាល់ សំរាប់ អ្នកសំរបសំរួល | ❑ បញ្ជាក់ និងសង្ខេបមតិដែលផ្តល់ដោយសិក្ខាកាម/អ្នកភូមិ។ ៥. អ្នកសំរបសំរួល ត្រូវដឹកនាំក្រុមអោយចេះសង្ខេបគំនិតរបស់ក្រុមពិភាក្សាស្តីពីការសំរបសំរួល។ អ្នកសំរបសំរួល គួរតែផ្តល់ពេលអោយបានគ្រប់គ្រាន់សំរាប់សិក្ខាកាមពិភាក្សាអំពីលំហាត់បង្ហួចចូហារីទាំង៤ ។ នឹងមានការពិពណ៌នាផ្សេងគ្នាចំពោះរូបគំនូរទាំងនោះ ប៉ុន្តែទោះជាយ៉ាងនោះក៏ដោយក៏មិនមានបញ្ហាអ្វីឡើយ ។ អនុញ្ញាតអោយសិក្ខាកាមទាំងអស់នោះបរិយាយអំពីគំនិតរបស់ពួកគេអោយល្អិតល្អន់ ។ គួរកត់សំគាល់ថា តួនាទីរបស់អ្នកសំរបសំរួល ត្រូវចាត់ចែងជាមុនទៅអោយបុរស នៅក្នុងពេលនោះដែរអោយស្ត្រីជាតំណាងអោយអ្នកភូមិ ។ គួរតែចាប់អារម្មណ៍ដឹងឮថា ប្រសិនបើសិក្ខាកាមកត់ត្រាលទ្ធផលនៃការពិភាក្សានេះ ហើយចង់បានអោយមានការផ្លាស់ប្តូរតួនាទីរវាងបុរស និងស្ត្រី ។ ចំណុចគន្លឹះនៃលំហាត់នេះ គឺសំរាប់អ្នកសំរបសំរួលចាប់យកនូវនិតប្លែកៗ និងការបកស្រាយនានា ព្រមទាំងដឹកនាំការពិភាក្សាសង្ខេបចំណុចសំខាន់ៗអំពីការសំរបសំរួល។ |

# វិធីសាស្ត្របណ្តុះបណ្តាល
# Training Methodology

វិធីសាស្ត្របណ្តុះបណ្តាល គឺជាឧបករណ៏ដែលអ្នកបណ្តុះបណ្តាលត្រូវមាន និងរៀបចំមុនពេលគេចាប់ផ្តើមបណ្តុះបណ្តាល ដើម្បីអោយដំណើរការបណ្តុះបណ្តាលមានលក្ខណៈសមស្របនឹងពេលវេលា ហើយទទួលបានជោគជ័យតាមអ្វីដែលគេចង់បាន។

មានវិធីសាស្ត្រជាច្រើន ដែលត្រូវបានប្រើប្រាស់នៅក្នុងវគ្គបណ្តុះបណ្តាល ហើយគ្រូបណ្តុះបណ្តាលគួរដឹងភាពខុសគ្នានៃវិធីសាស្ត្រទាំងអស់នោះ។ សម្រាប់ប្រធានបទ រឺសកម្មភាពបណ្តុះបណ្តាលនីមួយៗ គេគួរដឹងរបៀបជ្រើសរើសវិធីសាស្ត្រយកមកប្រើដើម្បីអោយការងារសម្រេចទៅបានជោគជ័យ ន័យមួយទៀតគ្រូបណ្តុះបណ្តាលគួរតែដឹងពេលវេលាប្រើប្រាស់វិធីសាស្ត្រអោយបានត្រឹមត្រូវ ហើយនិងយល់របៀបប្រើប្រាស់។

វិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រទាំងអស់ គឺអាស្រ័យទៅតាមគោលដៅមួយសម្រាប់វិធីសាស្ត្រមួយណាដែលពួកគេបានប្រើប្រាស់។ ឧទាហារណ៏ អ្នកចង់ផ្តល់ពតិមានទៅអោយសិក្ខាកាមនៅក្នុងវគ្គបណ្តុះបណ្តាលមួយ បង្ហាញពីរបៀបផ្សេងៗដែលធ្វើអោយការងារសម្រេចបានជោគជ័យ ផ្តល់ឱកាសអោយសិក្ខាកាមដើម្បីអោយមានការផ្លាស់ប្តូរយោបល់ និងបទពិសោធន៏ រឺក៏ទទួលគំនិតប្លែកៗពីប្រធានបទ។ សម្រាប់គោលដៅនីមួយៗ ដើម្បីបានលទ្ធផលល្អប្រសើរបំផុត អ្នកត្រូវប្រើប្រាស់វិធីសាស្ត្រណាដែលទាក់ទងនឹងគោលដៅនោះ។

| គោលដៅ | វិធីសាស្ត្រ |
|---|---|
| ផ្តល់ពតិមាន | សន្ទរកថា, បង្ហាញរូបភាព, តារាង (Chart) |
| ការផ្លាស់ប្តូរយោបល់ និងបទពិសោធន៏ | ការពិភាក្សា |
| បង្ហាញរបៀបធ្វើការងារបានជោគជ័យ | ការធ្វើបង្ហាញ |
| ទទួលគំនិតប្លែកៗអំពីប្រធានបទមួយ | ការបំផុសគំនិត |

នៅក្នុងការបណ្តុះបណ្តាល មានវិធីសាស្ត្រជាច្រើនយ៉ាងដែលអាចប្រើប្រាស់នៅក្នុងវគ្គមួយ ដែលតទៅនេះយើងសូមលើកយកនូវវិធីសាស្ត្រសំខាន់ៗដូចតទៅ :

- ការបំផុសគំនិត (Brainstorming)
- ការពិភាក្សាជាក្រុម (Group Discussion)
- ការធ្វើបង្ហាញ (Demonstration)
- ការសំដែងតួ (Role Play)
- ការសិក្សាករណី (Case Study)
- ការឧទ្ទេសនាម (Lecture)
- ទស្សនៈកិច្ចសិក្សា (Study Tour)

- ល្បែងពញ្ញាក់អារម្មណ៏ (Energize Game)

វិធីសាស្រ្តទាំងអស់ខាងលើនេះ ត្រូវបានអ្នកសំរបសំរួលប្រើប្រាស់នៅក្នុងវគ្គផ្សេងៗ ដោយស្របទៅតាមស្ថានភាពតំរូវការជាក់ស្តែងរបស់វគ្គ ហើយវាមានតួនាទី និងភាពខុសគ្នាដូចខាងក្រោម :

## ១. ការបំផុសគំនិត (Brainstorming)

ការបំផុសគំនិត គឺជាវិធីសាស្រ្តមួយដែលគេទាញយកនូវគំនិតផ្តួចផ្តើម (គំនិតច្នៃប្រឌិត) ពីអ្នកចូលរួម។ ជាវិធីសាស្រ្តដើម្បីបង្កើតអោយមានការបញ្ចេញគំនិត យោបល់ ឬសំណើរយ៉ាងឆាប់រហ័ស ដែលជាជំនួយដល់ការពិភាក្សាទៅលើប្រធានបទនីមួយៗ។

មនុស្សជាច្រើនខ្លាចមិនហ៊ានបញ្ចេញគំនិតរបស់គេ ព្រោះគេមានអារម្មណ៏ថាមានការសើចចំអក។ នៅក្នុងការបំផុសគំនិត គំនិតទាំងអស់ត្រូវបានគេទទួលយក និងត្រូវបានគេលើកយកមកពិភាក្សា។ វិធីសាស្រ្តនេះជួយអោយសិក្ខាកាមបញ្ចេញយោបល់ផ្សេងៗ ជួលកាលជាគំនិតប្រកបដោយការច្នៃប្រឌិត ។ លក្ខណៈពិសេស នៃការប្រើប្រាស់វិធីសាស្រ្តនេះ គឺ :

- ដើម្បីរិះរក និងប្រមូលគំនិតអោយបានច្រើនតាមតែអាចធ្វើទៅបាន និងជំរុញអ្នកចូលរួម អោយត្រិះរិះគំនិតគ្នាទៅវិញទៅមក
- អាចវាស់ និងដឹងពីកំរិតយល់ដឹងរបស់សិក្ខាកាម
- មិនត្រូវបដិសេធ រឺលុបចោលនូវគំនិតណាមួយឡើយ ហើយគំនិតនីមួយៗត្រូវបានទទួលយកដោយអ្នកសំរបសំរួល
- ដើម្បីបំផុសគំនិត គឺត្រូវធ្វើទៅតាមដំណាក់កាលចំនួន ៤ គឺ :

  - **កំនត់បញ្ហាដែលត្រូវដោះស្រាយ**
  - **អនុវត្តការបំផុសគំនិត :** ត្រូវសុំស្នើនូវគំនិតដែលជាដំណោះស្រាយ។ កត់គំនិតទាំងអស់នៅផ្ទាំងក្រដាសធំ សូម្បីតែគំនិតដែលមិនបានការ ក៏កត់ចូលទាំងអស់ដែរ(ល្អ ឬអាក្រក់)។ កុំធ្វើការពិភាក្សា កុំបញ្ជាក់ន័យ ឬផ្លាស់ប្តូរគំនិតនៅក្នុងដំណាក់កាលនេះ ។
  - **ពិនិត្យសារឡើងវិញ :** មើលបញ្ជីពិភាក្សា និងធ្វើអោយគំនិតទាំងនោះច្បាស់លាស់ចំពោះអ្នកទាំងអស់គ្នា។ លុបគំនិតដដែលៗ និង គំនិតដែលមិនទាក់ទងគ្នាចោល។
  - **ពិភាក្សាលើគំនិតដែលសេសសល់លើបញ្ជី ហើយសំរេចថាគំនិតណាមួយ ឬគំនិតណាខ្លះដែលមានប្រយោជន៏ទៅនឹងដំណោះស្រាយបញ្ហា ។**

## ២. ការពិភាក្សាជាក្រុម (Group Discussion)

ការពិភាក្សា គឺជាការជជែកវែកញែកផ្លាស់ប្តូរយោបល់ក្នុងក្រុមពិភាក្សា ដែលក្នុងនោះមានសមាជិកក្រុមពិភាក្សា និងអ្នកសំរបសំរួលជាអ្នកដឹកនាំការពិភាក្សានោះ។

វិធីសាស្ត្រនេះ អាចបង្កើនឱកាសអោយសមាជិកម្នាក់ៗមានការចូលរួមក្នុងការពិភាក្សា។ សមាជិកដែលមិនសូវមានយោបល់ តែមានគំនិតល្អនឹងមិនត្រូវបានគេឃើញនៅក្នុងការពិភាក្សាក្រុមធំនោះទេ ផ្ទុយមកវិញគេអាចរកឃើញនូវអ្នកចូលរួមនោះនៅក្នុងការពិភាក្សាក្រុមតូចនេះឯង។ បច្ចេកទេសដ៏ល្អនេះ គឺប្រមូលផ្តុំនូវសមត្ថភាព ចំណេះដឹង និងបទពិសោធន៍របស់អ្នកចូលរួម ដើម្បីឆ្ពោះទៅរកគោលដៅ ឬការយល់ដឹងរួម។ លក្ខណៈពិសេស នៃការប្រើប្រាស់វិធីសាស្ត្រនេះ គឺ :

- សិក្ខាកាមបានចូលរួមបញ្ចេញយោបល់ច្រើនជាងអ្នកសំរបសំរួល
- ផ្តល់ឱកាសអោយសិក្ខាកាមដែលអៀនឬមិនហ៊ានបញ្ចេញ អាចមានមតិ
- ផ្តល់នូវទស្សនៈផ្សេងៗគ្នាច្រើន
- ផ្តល់ឱកាសអោយសិក្ខាកាមបានឡើងបង្ហាញ និងរៀនស្វែងយល់ពីរបៀបបង្ហាញបានយ៉ាងល្អ
- ផ្តល់ឱកាសអោយសិក្ខាកាមទាំងអស់បានចោទសួរ និងឆ្លើយទៅតាមសមត្ថភាពដែលមាន ។

### ☞ ចំនុចសំខាន់ៗដែលត្រូវអនុវត្តនៅក្នុងការពិភាក្សាជាក្រុម

- រៀបចំបរិយាកាសជុំវិញខ្លួន អោយមានលក្ខណៈប្រសើរ :
    - អ្នកចូលរួមទាំងអស់ក្នុងក្រុមពិភាក្សា គប្បីអាចមើលឃើញមុខគ្នាទៅវិញទៅមកដោយអង្គុយជិតល្មម ដែលអាចស្តាប់គ្នាលឺ
    - ប្រសិនបើសមាជិកក្នុងក្រុមមិនបានស្គាល់គ្នាទៅវិញទៅមកទេ ពួកគេគប្បីណែនាំអោយស្គាល់គ្នា
    - គួរកុំមានការភ័យ ខ្លាចក្នុងការនិយាយ និងការបញ្ចេញគំនិត ឬសួរសំនួរផ្សេងៗ
- បង្ហាញអំពីគោលបំណង រឺប្រធានបទ នៃការពិភាក្សា
- កំនត់អោយបានច្បាស់លាស់នូវអ្វីដែលអ្នកចង់ធ្វើអោយសំរេចនៅចុងបញ្ចប់នៃការពិភាក្សា
- ចាត់តាំងអ្នកណាសំរបសំរួល អ្នកកត់ត្រា និងអ្នកឡើងបង្ហាញលទ្ធផល
- សួរសំនួរបើក ( ជៀសវាងសួរសំនួរបិទ)
- ប្រើជំនាញក្នុងការសំរបសំរួលដ៏សមរម្យ
    - ធ្វើអោយច្បាស់ថាសមាជិកក្នុងក្រុមទាំងអស់ចូលរួមក្នុងការពិភាក្សា។ សូមកុំអោយអ្នកណាម្នាក់ក្នុងក្រុម និយាយតែឯងច្រើនពេក។ បន្តផ្តល់យោបល់ផ្សេងៗ ចំពោះរឿងដែលសំខាន់ជាងគេ នៃការពិភាក្សា។
    - ធ្វើអោយដឹងច្បាស់ថាចំនុចនានាដែលបានលើកក្នុងកំឡុងពិភាក្សាត្រូវបានគេបកស្រាយច្បាស់លាស់
    - សង្ខេបនូវអ្វីដែលសមាជិកក្រុមបាននិយាយ និងសុំអោយសមាជិកក្នុងក្រុមសង្ខេបផងដែរ

### ☞ លក្ខណៈ នៃការពិភាក្សាតាមក្រុមដ៏ល្អមួយ

- សមាជិកក្នុងក្រុមទាំងអស់ត្រូវចូលរួមយ៉ាងសកម្ម ក្នុងការធ្វើអោយមានមតិយោបល់ផ្សេងៗ ក្នុងការបង្កើតនូវដំណោះស្រាយនានា និងការបញ្ចេញគំនិត
- អ្នកសំរបសំរួល ជាអ្នកថែរក្សានូវរចនាសម្ព័ន្ធ រឺគំរោងនៃក្រុមពិភាក្សា

- ធ្វើអោយបរិយាកាសធូរស្រាល និងជួយគ្នាទៅវិញទៅមក
- អ្នកចូលរួមទាំងអស់មានទំនុកចិត្តក្នុងការចូលរួមបញ្ចេញយោបល់
- អនុញ្ញាតអោយអ្នកចូលរួម ប្រើនូវគោលការណ៍ រឺរឿងពិតដែលគេបានរៀនមកហើយ
- ដកស្រង់នូវបទពិសោធន៍ និងអាក្បកិរិយារបស់អ្នកចូលរួមទាំងអស់ ។

## ៣. ការធ្វើបង្ហាញ (Demonstratioin)

គឺជាការធ្វើបង្ហាញដល់សិក្ខាកាមពីរបៀបធ្វើអ្វីមួយជាជំហានៗ ។ អាចផ្តល់ពត៌មានបានច្រើនជាងធ្វើការឧទ្ទេសនាមមេរៀន ដោយផ្ទាល់មាត់ ។ ការធ្វើបង្ហាញច្រើនតែធ្វើឡើងនៅពេលអនុវត្តផ្ទាល់ ដែលក្នុងនោះសិក្ខាកាមត្រូវធ្វើលំហាត់ក្រោមការត្រួតពិនិត្យរបស់គ្រូបណ្តុះបណ្តាល ។ លក្ខណៈពិសេស នៃវិធីសាស្រ្តនេះ គឺជួយអោយអ្នកចូលរួមមានការចាប់អារម្មណ៍ និងមានភាពងាយស្រួលនៅក្នុងការទទួលយកចំណេះដឹង ។

**របៀបធ្វើបង្ហាញ :**

- រៀបចំបរិយាកាសជុំវិញខ្លួន : អ្នកចូលរួមទាំងអស់នៅក្នុងក្រុមពិភាក្សា គប្បីមើលមុខគ្នាឃើញទៅវិញទៅមកហើយ អង្គុយអោយជិតល្មមដែលអាចឮអ្នកដទៃនិយាយបានច្បាស់ ។ ប្រសិនបើសមាជិកក្នុងក្រុមមិនស្គាល់គ្នាច្បាស់លាស់ទេ ពួកគេគប្បី ណែនាំអោយស្គាល់គ្នា ។ គួរកុំអោយមានការភ័យខ្លាចចំពោះការនិយាយ និងបញ្ចេញគំនិត រឺសួរសំណួរផ្សេងៗ ។
- អ្នកសំរបសំរួលពន្យល់នូវគោលបំណងនៃការធ្វើបង្ហាញ
- អ្នកសំរបសំរួលបង្ហាញពីទំរង់ការទៅក្រុម : សូមសរសេរ រឺប្រាប់អោយច្បាស់ចំពោះជំហាននៅក្នុងទំរង់ការ ធ្វើដូចនេះ អ្នកចូលរួមនឹងអាច ធ្វើបង្ហាញមកអ្នកសំរបសំរួលបានវិញ
- អ្នកចូលរួមសួរសំណួរនានា និងពិភាក្សាពីទំរង់ការនោះ
- អ្នកចូលរួមអនុវត្ត ដោយមានការត្រួតពិនិតពីអ្នកសំរបសំរួល ។

## ៤. ការសំដែងតួ (Role Play)

ជាវិធីសាស្រ្តនៃការបណ្តុះបណ្តាល រឺផ្សព្វផ្សាយ ដែលបំផុសនូវចំណាប់អារម្មណ៍ លើកទឹកចិត្តអោយមានការចូលរួមពីសិក្ខាកាម និងធ្វើអោយងាយស្រួលក្នុងការចងចាំតាមរយៈការប្រើប្រាស់ស្ថានភាពប្រហាក់ប្រហែលនឹងស្ថានភាពពិត ។ លក្ខណៈពិសេស នៃការប្រើប្រាស់វិធីសាស្រ្តនេះ គឺ :

- ផ្តល់អោយសិក្ខាកាមបានប្រើការស្រមៃរបស់ពួកគេ និងអាចអនុវត្តនូវចំណេះដឹង បទពិសោធន៍របស់ពួកគេ
- សិក្ខាកាមអាចស្គាល់ពីចំណុចខ្លាំង និងខ្សោយរបស់ខ្លួន និងមានការជឿជាក់លើខ្លួនឯង ដោយមានការកែលំអពីអ្នកផ្សេងទៀត

- សិក្ខាកាមអាចមានបទពិសោធន៍ល្អនៅពេលដែលគាត់បានជួបនៅស្ថានភាពជាក់ស្តែង
- សិក្ខាកាមមានការទំនាក់ទំនងជាមួយក្រុមកាន់តែជិតស្និត

## ៥. ការសិក្សាករណី (Case Study)

ករណីសិក្សា គឺជាការសិក្សាពីប្រវត្តិ រឺព្រឹត្តិការណ៏ដែលកើតឡើងតាមលំដាប់លំដោយ ទាក់ទងទៅនឹងបុគ្គល ក្រុម គ្រួសារ សហគមន៏ សមាគម រឺអង្គការផ្សេងៗ។ វាជាមធ្យោបាយមួយ ដែលមានភាពស្ទាត់ស្ទៀមសំរាប់ការសិក្សាមើលស្ថានការណ៏ ដែលអាចស្រដៀងគ្នាទៅនឹងអ្វីដែលសិក្ខាកាមនឹងជួបប្រទះ។ វិធីសាស្ត្រនេះគេត្រូវអនុវត្តន៏ ដោយវិភាគ និងពិភាក្សាករណីជាក់ស្តែង ហើយអ្នកសិក្សាត្រូវរៀបចំផែនការសំរាប់ដោះស្រាយបញ្ហាដែលគេរកឃើញក្នុងករណីសិក្សានេះ។ គេធ្វើបង្ហាញករណីសិក្សាដោយផ្ទាល់មាត់ ជារបាយការណ៏តាមការបញ្ចាំងភាពយន្ត រឺដោយប្រព័ន្ធឃោសនាផ្សេងៗ។ ការសិក្សានេះនឹងជួយអោយសមាជិកក្រុមរៀនសូត្រ អាចបង្កើនជំនាញខាងវិភាគ និងដោះស្រាយបញ្ហា ។

ករណីសិក្សាមិនចាំបាច់រៀបចំបញ្ជីសំណួរទេ ប៉ុន្តែគួរព្រាងគំនិតដើម្បីប្រមូលពត៌មានអ្វី ដែលចាំបាច់ មានដូចជា:

- ប្រមូល និងចងក្រងប្រវត្តិ រឺព្រឹត្តិការណ៏ដែលកើតមានកន្លងមក
- ការប្រែប្រួលនៅពេលបច្ចុប្បន្ន បន្ទាប់ពីបានទទួលសេវាកម្មពីគំរោង រឺសេវាកម្មផ្សេងៗ
- អង្កេតជាទូទៅ តាមរយៈការពិនិត្យរាល់ស្ថានភាពជាក់ស្តែង (រឺរឿងរ៉ាវជីវិតពិត) នៃបុគ្គល រឺគ្រួសារនីមួយៗ
- ស្វែងយល់ពីចំណាប់អារម្មណ៏របស់អ្នកទទួលផល
- សុំជាយោបល់ រឺអនុសាសន៏
- ធ្វើសេចក្តីសន្និដ្ឋាន

### ឧទាហរណ៍ករណីសិក្សា

### ការធ្វើបង្ហាញ ប្រើប្រាស់ពូជ ជី គៀរពង្រាបដី លើដំណាំស្រូវ

នៅក្នុងភូមិរាមសេនា ឃុំល្វា ស្រុកបវេល ខេត្តបាត់ដំបង

ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២

ពូផាយ ឈឿប ជាកសិករ អាយុ ៥៨ឆ្នាំ ។ ប្រពន្ធគាត់ឈ្មោះ ស៊ីម រ៉ាំង អាយុ៤៥ឆ្នាំ។ គ្រួសារគាត់កូន៥នាក់រស់នៅក្នុងបន្ទុក។ គ្រួសារគាត់មានជីវភាពរស់ដោយផ្អែកលើការធ្វើកសិកម្ម ហើយមានទីលំនៅនៅក្នុងភូមិរាមសេនា ឃុំល្វា ស្រុកបវេល ខេត្តបាត់ដំបង។

នៅមុនឆ្នាំ២០០០ គ្រួសារគាត់មានដីស្រែចំនួន២ហិកតា និងដីចំការចំនួន ០,៥ហិកតា។ គ្រួសារពូផាយ ឈឿប រស់នៅក្នុងជីវភាពក្រីក្រ ពីព្រោះក្រៅពីរបរធ្វើស្រែចំការ គាត់មិនមានលទ្ធភាពប្រកបរបរផ្សេងទៀតឡើយ។ ម្យ៉ាងវិញទៀតនៅពេលនោះ ទិន្នផលស្រូវជាមធ្យមដែលគាត់ទទួលបានក្នុងមួយហិកតាបានត្រឹមតែ១៥០០គីឡូក្រាមតែប៉ុណ្ណោះ ទោះបីគាត់បានប្រើប្រាស់ជីច្រើនលើសលប់ តាមការណែនាំរបស់អ្នកជិតខាងយ៉ាងណាក៏ដោយ។ ហេតុនេះ ហើយទើបគ្រួសារគាត់ជួបប្រទះនូវកង្វះ

ខាតស្បៀង។ ក្នុងមួយឆ្នាំៗ គាត់តែងតែខ្ចីបុលគេ ចំនួន ២ ០០០ ០០០រៀល ដើម្បីបង្គ្រប់លើតំរូវការគ្រួសារ។

នៅឆ្នាំ២០០០ ពូផាយ ឈឿប បានត្រូវជ្រើសរើសធ្វើជាកសិករបង្ហាញការប្រើប្រាស់ពូជស្រូវ ជី និងកៀរពង្រាប របស់កម្មវិធីកែលំអកសិកម្ម នៃគំរោងអភិវឌ្ឍន៍កសិកម្មគាំទ្រកម្មវិធីសិលា។ ចាប់តាំងពីពេលនោះមក គាត់បានចូលរួមការបណ្តុះបណ្តាលអំពីការប្រើប្រាស់ជីលើដំណាំស្រូវ ការប្រើប្រាស់ពូជ និងការកៀរពង្រាបដី។ គាត់ខិតខំអនុវត្តតាមបច្ចេកទេសទាំងនេះ និងការណែនាំផ្សេងៗទៀតពីគំរោងបានយ៉ាងល្អ។ ដោយសារការអនុវត្តតាមបច្ចេកទេស ទាំងនេះលើការធ្វើស្រែនេះហើយ ទើបធ្វើអោយទិន្នផលស្រូវគាត់បានកើនឡើងរហូតដល់២០០០ គីឡូក្រាម ក្នុងមួយហិកតា។ ដោយសារឃើញជាក់ស្តែងនូវការរីកចំរើននេះហើយ ទើបគ្រួសាររបស់ពូផាយ ឈឿប បានប្រើប្រាស់បច្ចេកទេសទាំងនេះលើការធ្វើស្រែរបស់រហូត ទោះបីគ្មានការជួយគាំទ្រ រឺឧបត្ថម្ភពីគំរោងក៏ដោយ។ ឥឡូវនេះគ្រួសារ គាត់មានស្បៀងហូបគ្រប់គ្រាន់ហើយ។

នៅក្នុងឆ្នាំ២០០៣ ផលិតផលស្រូវគាត់កើនបានរហូតដល់ ១៧៦ បាវ ដែលគិតជាប្រាក់ស្មើនឹង ៨ ០១៣ ០០០ រៀល។

ឥឡូវនេះគាត់សប្បាយចិត្តណាស់ចំពោះការរីកចំរើនដែលកើតមានចំពោះគ្រួសារគាត់។ គាត់បញ្ជាក់ថាការរីកចំរើនទាំងនេះ កើតមានឡើងទៅបានគឺអាស្រ័យទៅដោយការអនុវត្តតាមបច្ចេកទេសថ្មីដែលផ្តល់ដោយគំរោង ពិសេសបច្ចេកទេសប្រើប្រាស់ជីលើដំណាំស្រូវនេះឯង។ គាត់បញ្ជាក់ទៀតថា គ្រួសារគាត់ឈប់ជំពាក់បំណុលគេទៀតហើយ។

## ៦. ការឧទ្ទេសនាម (Lecture)

ជាទូទៅ វិធីសាស្ត្រដែលគេបានប្រើប្រាស់សំរាប់ការផ្សព្វផ្សាយនូវចំណេះដឹងផ្សេងៗ ការឧទ្ទេសនាមជាញឹកញាប់ត្រូវបានប្រកាន់យកដើម្បីរៀបរាប់ដែលមានសភាពប្រហាក់ប្រហែលគ្នានឹងសន្ទរកថា រឺការធ្វើបទបង្ហាញដែរ។ ប៉ុន្តែអ្វីដែលជាលក្ខណៈរួមរបស់ការឧទ្ទេសនាម គឺជាការពិតវាខ្វះខាតនូវការពិភាក្សា និងសកម្មភាពរស់រវើក រវាងអ្នកចូលរួមស្តាប់ និងអ្នកធ្វើឧទ្ទេស-នាម។ ជាទូទៅឱកាស នៃការសួរសំនួរគឺត្រូវបានអនុញ្ញាតិអោយនៅក្រោយពេលការធ្វើឧទ្ទេសនាមចប់ ហើយវាជាការកំរណាស់ដែលត្រូវបានបើកអោយមានសំណួរនៅក្នុងពេលធ្វើឧទ្ទេសនាម។ វាជាមធ្យោបាយសំខាន់សំរាប់ផ្សព្វផ្សាយពតិមានជាមូលដ្ឋានអំពីសកម្មភាពអនាគត។ ការឧទ្ទេសនាម គឺជាការនិយាយផ្ទាល់មាត់ពីប្រធានបទណាមួយដែលបានរៀបចំឡើងដោយយកចិត្តទុកដាក់។ វិធីនេះអាចប្រើដើម្បីបង្ហាញពីទស្សនៈនៃប្រធានបទចំរូងចំរាស់ណាមួយដើម្បីអោយអ្នកស្តាប់កាន់តែចាប់អារម្មណ៏ រឺដើម្បីបង្កើនការត្រិះរិះ និងការសិក្សាស៊ីជំរៅបន្ថែម នៃបញ្ហាណាមួយដោយបើកទូលាយអោយមានការពិភាក្សារួមគ្នា។ វិធីសាស្ត្រនេះប្រើប្រាស់បានសំរាប់ការប្រជុំធំ តូច និងមានលក្ខណៈងាយស្រួលក្នុងការរៀបចំ។ បន្ទាប់ពីការធ្វើឧទ្ទេសនាម គេគួរធ្វើការពិភាក្សាជាក្រុម ដើម្បីបញ្ជាក់អោយកាន់តែច្បាស់នូវចំនុចដែលបានបង្ហាញ។

### គុណសម្បត្តិ

- ប្រសិនបើបទឧទ្ទេសនាម ត្រូវបានរៀបចំឡើងដោយសមស្រប ត្រឹមត្រូវ ហើយនិស្សិតទាំងអស់ត្រូវបានលើកទឹកចិត្តគ្រប់គ្រាន់ អ្នកចូលរួមទាំងអស់នឹងអាចទទួលបាននូវចំណេះដឹងប្រកបដោយប្រសិទ្ធិភាព ទាំងអ្នកដែលឆាប់ចាប់បានទាំងអ្នកដែលមានភាពយឺតយ៉ាវនៅក្នុងការសិក្សា។
- ពតិមានក្នុងបរិមាណច្រើនអាចផ្ទេរបានយ៉ាងឆាប់រហ័សតាមរយៈបទឧទ្ទេសនាម

- អ្នកចូលរួមស្តាប់គ្រប់ប្រភេទ នឹងអាចទទួលយកបានយ៉ាងល្អពីការធ្វើបទឧទ្ទេសនាម ប្រសិនបើអ្នកទាំងអស់គ្នាអាចមើលឃើញ និងស្តាប់លឺអ្នកធ្វើឧទ្ទេសនាម
- គ្រប់ការធ្វើឧទ្ទេសនាមទាំងអស់ អាចគ្រប់គ្រងបានល្អនូវអ្វីដែលខ្លួនបាននិយាយ និងពេលណាដែលខ្លួនត្រូវនិយាយ ពីព្រោះការធ្វើឧទ្ទេសនាមបានកំណត់ច្បាស់លាស់ចំពោះពេលវេលា ដែលមិនអោយមានការរំខាន ពីអ្នកចូលរួម ។

**គុណវិបត្តិ**

- ការធ្វើឧទ្ទេសនាម គឺទាមទាមនូវជំនាញ និងមានការយកចិត្តទុកដាក់ និងផ្តោតអារម្មណ៍សំរាប់រយៈពេលច្រើនម៉ោង នៅក្នុងករណីខ្លះ
- ការចូលរួមពិភាក្សាពីសិក្ខាកាមមានកំរិតជាអប្បបរិមា, ការធ្វើឧទ្ទេសនាម ត្រូវបានរៀបចំឡើងសំរាប់ការរៀនសូត្រ ដែលមានលក្ខណៈមិនសកម្ម
- មានតែគំនិតយោបល់ពីអ្នកធ្វើឧទ្ទេសនាមតែប៉ុណ្ណោះ ដែលត្រូវបានបង្ហាញឡើង
- ការឆ្លុះបញ្ចាំង និងការបង្កើតថ្មីនៅក្នុងដំណើរការវគ្គ មានកំរិត

## ៧. ទស្សនៈកិច្ចសិក្សា (Study Tour)

គឺជាការចុះទៅមើល និងសិក្សាដោយផ្ទាល់ដល់ទីកន្លែងអនុវត្ត។ វាជាវិធីសាស្រ្តមួយដ៏មានប្រសិទ្ធិភាពបំផុត ចំពោះការផ្តល់នូវចំណេះដឹងអំពីអ្វីមួយដើម្បីបង្កើនការចាប់អារម្មណ៍ និងផ្សារភ្ជាប់ការសិក្សាទ្រឹស្តីទៅនឹងការអនុវត្តន៍ ជាក់ស្តែង។

## ៨. ល្បែងពញ្ញាក់អារម្មណ៍ (Energize Game)

ជាមធ្យោបាយមួយដែលធ្វើអោយសមាជិកទាំងឡាយរបស់ក្រុមចាប់ផ្តើមស្គាល់ និងស្និទ្ធស្នាលគ្នា។ វិធីនេះអាចត្រូវបានប្រើសំរាប់បំបាត់ការនឿយហត់ និងធ្វើអោយសិក្ខាកាមរៀបចំខ្លួនជាស្រេចដើម្បីរៀនសូត្របន្ត។ ជាទូទៅ ល្បែងពញ្ញាក់អារម្មណ៍ត្រូវបានអនុវត្តដោយមានអត្ថន័យទាក់ទងនឹងប្រធានបទដែលកំពុងលើកឡើង ។

# អំពីគ្រូបណ្ដុះបណ្ដាល
# About Trainers

ការបណ្ដុះបណ្ដាល គឺជាមធ្យោបាយយ៉ាងសំខាន់ក្នុងការកសាងសមត្ថភាព។ ការបណ្ដុះបណ្ដាលមានអត្ថប្រយោជន៍យ៉ាងច្រើនដោយផ្ដល់ជាវេទិកាសំរាប់មនុស្សជួបគ្នា ហើយរៀនសូត្រពីគ្នាទៅវិញទៅមក និងអនុវត្តនូវអ្វីដែលគាត់បានរៀនសូត្រ ព្រមទាំងមានឱកាសសាកសួរសំណួរផ្សេងៗ និងផ្លាស់ប្ដូរបទពិសោធន៍។ ដើម្បីជំរុញអោយវគ្គបណ្ដុះបណ្ដាលមួយ ប្រព្រឹត្តិទៅប្រកបដោយប្រសិទ្ធិភាព និងសំរេចគោលដៅតាមការគ្រោងទុក ជាការចាំបាច់ណាស់ ដែលវគ្គបណ្ដុះបណ្ដាលនោះ ត្រូវមានគ្រូបណ្ដុះបណ្ដាល ដែលជាអ្នកសំរបសំរួលនៅក្នុងវគ្គបណ្ដុះបណ្ដាល។

## ១. តួនាទីសំខាន់ៗចំបងសំរាប់គ្រូបណ្ដុះបណ្ដាល

គ្រូបណ្ដុះបណ្ដាល ត្រូវបំពេញតួនាទីសំខាន់ៗចំបងចំនួនពីរដូចខាងក្រោម :

១. ត្រូវធ្វើយ៉ាងណាអោយក្រុមសិក្ខាកាមសំរេចកិច្ចការ រឺគោលបំណងនៃការរៀនសូត្ររបស់វគ្គបណ្ដុះបណ្ដាល ឧទាហរណ៍ដូចជាអោយសិក្ខាកាមទទួលបាននូវចំណេះដឹង និងជំនាញអ្វីមួយជាដើម ។ល ។

២. ត្រូវបង្កលក្ខណៈអោយមានការចូលរួមបញ្ចេញមតិយោបល់ គឺមានន័យថាធ្វើយ៉ាងណាអោយសិក្ខាកាមម្នាក់ៗពាក់ព័ន្ធក្នុងការពិភាក្សា និងសំរេចចិត្តលើប្រធានបទពិភាក្សាផ្សេងៗ ហើយមតិយោបល់គេម្នាក់ៗនោះត្រូវបានគេស្ដាប់ និងគោរពចំពោះគ្នាទៅវិញទៅមក ។

កត្តាសំខាន់ជាងគេនោះ គឺគ្រូបណ្ដុះបណ្ដាលត្រូវព្យាយាមធ្វើយ៉ាងណាអោយមានតុល្យភាពគ្នារវាងការសំរេចបាននូវកិច្ចការដែលត្រូវធ្វើក្នុងការបង្រៀន និងការលើកទឹកចិត្តអោយមានការចូលរួមបញ្ចេញមតិយោបល់យ៉ាងសកម្មពីសិក្ខាកាម។ គ្មានផ្នែកណាមួយអាចមានឥទ្ធិពលគ្របដណ្ដប់លើផ្នែកណាមួយបានឡើយរវាងផ្នែកទាំងពីរនេះ។

## ២. សមត្ថភាពដែលគ្រូបណ្ដុះបណ្ដាលត្រូវមាន :

គ្រូបណ្ដុះបណ្ដាលអាចបង្រៀនបានល្អ នៅពេលដែលខ្លួនយល់ច្បាស់លាស់អំពីប្រធានបទដែលត្រូវបង្រៀន ព្រមទាំងមានជំនាញ និងវិធីសាស្ត្រសមស្របក្នុងការបង្រៀន ដើម្បីសំរេចជោគជ័យតាមគោលបំណងរបស់វគ្គ។ ដើម្បីឆ្លើយតបបាននឹងលទ្ធផលនេះ គ្រូបណ្ដុះបណ្ដាលគួរមានសមត្ថភាព ដូចខាងក្រោម :

- មានការយល់ដឹងស៊ីជំរៅអំពីវិស័យដែលខ្លួនបង្រៀន
- មានជំនាញក្នុងការរៀបចំ និងចាត់ចែងក្រុមពិភាក្សា
- មានជំនាញក្នុងការបង្ហាញពតិមាន
- មានជំនាញក្នុងការធ្វើអោយមានតុល្យភាពគ្នារវាងការចូលរួមមតិពីសិក្ខាកាម បុរស និងស្ត្រី

- មានសមត្ថភាពក្នុងការតែងការបង្រៀន បង្កើត និងប្រើប្រាស់គ្រឿងសំភារៈជំនួយ និងឯកសារចែកក្នុងការបង្រៀនបានត្រឹមត្រូវ ។

គ្រូបណ្តុះបណ្តាលត្រូវចងចាំថា ខ្លួនជាអ្នកសំរបសំរួលវគ្គបណ្តុះបណ្តាលមួយដែលមានសិក្ខាកាមសុទ្ធតែជាមនុស្សពេញវ័យ ដែលការរៀនសូត្ររបស់គាត់ ត្រូវតែមានលក្ខណៈចូលរួម គឺជាការរៀនសូត្រដែលផ្តោតការយកចិត្តទុកដាក់ធ្វើយ៉ាងណាអោយអ្នករៀនអាចអភិវឌ្ឍន៍សមត្ថភាពរបស់ខ្លួនក្នុងការគិតពិចារណា វិភាគ វែកញែក និងទាញយកចំនុចរៀនសូត្រ រឺដំណោះស្រាយសំរាប់បញ្ហារបស់គេដោយខ្លួនគេផ្ទាល់ ។

## ៣. បញ្ហា និងវិធីសាស្ត្រដោះស្រាយសំរាប់គ្រូបណ្តុះបណ្តាល

នៅក្នុងវគ្គបណ្តុះបណ្តាលមួយ គ្រូបណ្តុះបណ្តាលតែងតែជួបប្រទះនូវបញ្ហា រឺឧបសគ្គជាច្រើន ដែលទាមទារអោយចេះដោះស្រាយប្រកបដោយភាពវៃឆ្លាត ។ បញ្ហាដែលតែងតែជួបប្រទះនោះរួមមាន :

-មានអ្នកនិយាយច្រើនតែឯង រឺអ្នកមិននិយាយសោះ

-មានអ្នកនិយាយក្រៅសាច់រឿង ឬនិយាយចាកប្រធានបទ

-មានការខ្វែងគំនិតគ្នា ឈានទៅរកទំនាស់

-មានអ្នកជជែកគ្នា មិនយកចិត្តទុកដាក់ស្តាប់អ្នកដទៃនិយាយ

-មានអ្នកសំរេចចិត្តតាមគ្នា

-មានការអៀនខ្មាស់ច្រើន

-មានអ្នកជក់បារី និងពិសាស្រា ( ករណីបណ្តុះបណ្តាលនៅតាមសហគមន៍)

-មានអ្នកងងុយដេក

-មានអ្នកសួរច្រើន និងកាច់អ្នកសំរបសំរួល

-មានអ្នកដែលមនឋានៈខ្ពស់ ឬចំណាស់

-មានអ្នកមានចំណេះដឹងមិនស្មើគ្នា ឬ ចំនេះដឹងទាប

☛ **ប្រសិនបើគ្រូបណ្តុះបណ្តាលជួបប្រទះនូវបញ្ហាទាំងអស់នេះហើយ តើត្រូវដោះស្រាយយ៉ាងដូចម្តេច? ខាងក្រោមនេះ គឺជាការលើកឡើងនូវបទពិសោធន៍ខ្លះក្នុងការដោះស្រាយទៅតាមករណីផ្សេងៗគ្នា :**

**ក. ករណីមានអ្នកងងុយគេង :** គ្រូបណ្តុះបណ្តាលអាចប្តូរបរិយាកាសក្នុងការសំរបសំរួល ដោយក្នុងនោះអាចដឹកនាំសិក្ខាកាមទាំងអស់អោយនិទានរឿងកំប្លែងខ្លី, រឺលេងល្បែងពញ្ញាក់អារម្មណ៍, ដើរទៅជិតសិក្ខាកាមរូបនោះហើយផ្តល់សំណួរសំរាប់អោយឆ្លើយ, បង្កការអបអរសាទរដោយសំលេងទះដៃ, ប្តូរទីកន្លែងសំរាប់សិក្ខាកាមរូប នោះ ។ល ។

**ខ. ករណីមានការជជែកគ្នាក្នុងថ្នាក់មិនស្តាប់អ្នកសំរបសំរួលពន្យល់ :** គ្រូបណ្តុះបណ្តាលអាចសូមអោយសិក្ខាកាមដែលកំពុងជជែកគ្នាអោយមកជួយសរសេរ រឺកត់ត្រាសំរាប់ខ្លួន, ដាក់លំហាត់ រឺកិច្ចការ រឺប្រធានបទសំរាប់អនុវត្ត

ជាក់ស្តែង, ធ្វើការប្តូរទីកន្លែងសិក្ខាកាមដែលជជែកគ្នានោះអោយនៅឆ្ងាយពីគ្នា, ដើរទៅជិតសិក្ខាកាមទាំងនោះ ហើយផ្តល់សំណួរសំរាប់អោយឆ្លើយ រឺអោយសិក្ខាកាមនោះអានន្ទូវអត្ថបទអ្វីមួយ ។ល ។

**គ. ករណីមានការសួរសំណួរច្រើន រឺកាច់គ្រូបណ្តុះបណ្តាល :** គ្រូបណ្តុះបណ្តាលត្រូវតែយកចិត្តទុកដាក់ និងពូកែស្តាប់, បង្វែរសំណួរដែលបានសួរនោះទៅអោយក្រុមសិក្ខាកាមទាំងមូលចូលរួមឆ្លើយ, បំផុសគំនិតដល់ក្រុមសិក្ខាកាម ទាំងអស់, ទទួលយកន្ទូវគំនិតសិក្ខាកាម ។ល ។

**ឃ. ករណីមានសិក្ខាកាមដែលមានឋានៈខ្ពស់ :** គ្រូបណ្តុះបណ្តាលត្រូវព្យាយាមពង្រឹងស្មារតីអោយរឹងប៉ឹងកុំតក់ស្លុត, ត្រូវផ្តល់នូវការប្រៀបធៀបគំនិតដែលបានលើកឡើងជាមួយគំនិតសិក្ខាកាមដទៃទៀត, ចេះលើកទឹកចិត្ត, ធ្វើទឹកមុខរីករាយ, បង្កើតទំនាក់ទំនងល្អ, ចេះបង្វែរសំណួរទៅកាន់សិក្ខាកាមផ្សេងទៀត ។ល ។

## ៤. ការប្រើប្រាស់កាយវិការ និងអាកប្បកិរិយាសំរាប់គ្រូបណ្តុះបណ្តាល

ជាទូទៅអ្នកបង្រៀន ឬអ្នកសំរបសំរួល នៅពេលបង្រៀនតែងតែគិតថាត្រូវធ្វើយ៉ាងណាអោយអកប្បកិរិយាដែលខ្លួនសំដែងចេញមក មានភាពសមរម្យថ្លៃថ្នូរសំរាប់សិក្ខាកាម តែគេមិនបានគិតថាតើត្រូវធ្វើយ៉ាងណាអោយមានការប្រើកាយវិការរបស់គេនោះ ជួយលើកទឹកចិត្ត និងគាំទ្រការសិក្សារៀនសូត្ររបស់សិក្ខាកាមទេ ។

គោលបំនងសំខាន់នៃការប្រើប្រាស់របស់កាយវិការ គឺដើម្បីបង្កើនការទំនាក់ទំនងល្អ ការចូលរួម ជំនឿទុកចិត្ត និងការលើកទឹកចិត្តរបស់សិក្ខាកាមក្នុងការរៀនសូត្ររបស់សិក្ខាកាម ។ គ្រូបណ្តុះបណ្តាលត្រូវប្រើប្រាស់នូវកាយវិការសំខាន់៧ដូចតទៅ :

**ក. ទឹកមុខ**

- ប្រើនូវចំណាប់អារម្មណ៍មួយចំនួនដូចជា ការភ្ញាក់ផ្អើល ព្រួយបារម្ភ សប្បាយរីករាយ
- មិនត្រូវផ្តោតអារម្មណ៍ទៅលើរឿងដែលសិក្ខាកាមបានលើកឡើងហួសហេតុពេក ដែលអាចជាហេតុធ្វើអោយមានការប្រែប្រួលទឹកមុខ
- ត្រូវចាប់អារម្មណ៍ និង ស្វែងយល់ពីទឹកមុខរបស់សិក្ខាកាម ព្រោះវាអាចស្តែងចេញនូវអារម្មណ៍ផ្សេងៗរបស់ពួកគេ

**ខ. ភ្នែក**

- ចាប់ផ្តើមមើលទៅលើសិក្ខាកាមនៅខាងក្រោយមុន បន្ទាប់មកមើលទៅឆ្វេងទៅស្តាំ
- សំឡឹងមើលសិក្ខាកាមនៅក្នុងបន្ទប់អោយបានគ្រប់គ្នា តែមិនត្រូវប្រើរយៈពេលយូរអោយលើសពី ២-៣នាទីទេ លុះត្រាតែអ្នកនិយាយជាមួយសិក្ខាកាមនោះ
- ជៀសវាងការសំឡឹងទៅរកសិក្ខាកាមណាមួយមិនដាក់ភ្នែក

**គ. ពាក្យសំដី**

- ត្រូវប្រើពាក្យសំដីសុភាពរាបសារ ទន់ភ្លន់ និយាយច្បាស់ៗ ជៀសវាងនិយាយញាប់ ហើយនិយាយច្រើនពេក
- ពេលនិយាយទៅកាន់សិក្ខកាម ត្រូវបែរមុខទៅកាន់សិក្ខកាម ជៀសវាងនិយាយដោយបែរមុខចេញពីសិក្ខកាម រឺបែរមុខទៅកាន់ក្តារខៀន ។

- ត្រូវមានការនិយាយកំប្លែងលេងខ្លះ តែជៀសវាងនិយាយកំប្លែង រឺនិយាយលេងសើចច្រើនពេក ដែលធ្វើអោយខូចសណ្តាប់ធ្នាប់របស់ការរៀនសូត្រ ។
- និយាយទៅកាន់សិក្ខាកាមនៅខាងក្រោយ ដោយប្រើសំលេងឮជាងធម្មតា
- ប្រើសំលេងលើកដាក់ ប្រកបដោយជនឿទុកចិត្ត ភាពជោគជ័យ និងដោយរំភើប ឬទុក្ខព្រួយបារម្ភទៅតាមសាច់រឿង រឺប្រធានបទ
- និយាយអោយច្បាស់ពេញពាក្យទាំងមូល ជៀសវាងការនិយាយលេបពាក្យនៅចុងឃ្លា រឺនិយាយរដិបរដុបច្រើនដង
- និយាយសង្កត់ទៅលើពាក្យដែលមានសារៈសំខាន់ចង់អោយសិក្ខាកាមចាប់អារម្មណ៍
- និយាយបញ្ជាក់ម្តងទៀតនូវពាក្យសំខាន់ ដោយការសង្កត់សំលេងលើពាក្យនោះ

**ឃ. កាយវិការ**

- ជៀសវាងការប្រើម្រាមដៃមួយចង្អុលចំទៅសិក្ខាកាម នៅពេលដែលចង់អោយសិក្ខាកាមរូបនោះមានយោបល់
- ឈរអោយត្រង់ និងអោយបានសមរម្យនៅត្រង់កន្លែងដែលមិនរំខាន រឺប៉ះពាល់ដល់ចំណាប់អារម្មណ៍របស់សិក្ខាកាម
- គួរផ្លាស់ប្តូរទីកន្លែងដែលឈរ ឬដើរចុះឡើងអោយបានញឹកញាប់ ដោយមិនគួរឈរនៅមួយកន្លែងទេ, ក្នុងករណីដែលត្រូវដើរទៅរកក្តារខៀនវិញ ត្រូវជៀសវាងកុំដើរដោយបែរខ្នងដាក់សិក្ខាកាម គួរតែដើរថយក្រោយ
- បើចង់មើលទៅក្រោយ ត្រូវបែរខ្លួនមកវិញ ដោយគួរជៀសវាងការប្រើកងាកមើល
- ជៀសវាងប្រើដៃច្រត់លើតុ រឺច្រត់ចង្កេះ រឺការប្រើកាយវិការច្រង៉េងច្រង៉ាងផ្សេងៗទៀតហួសហេតុពេក

**ង. សំលៀកបំពាក់**

- ជៀសវាងស្លៀកពាក់សំលៀកបំពាក់អោយបានសមរម្យ ជៀសវាងការប្រើសំលៀកបំពាក់តុបតែងហួសហេតុពេក និងមិនត្រូវមានពណ៌ស្រស់ធ្វើអោយចាំងភ្នែក រឺជាពណ៌ដែលឆើតឆាយពេក
- ត្រួតពិនិត្យមើលឡេវអាវ និងខ្សែរូតខោ សំពត់មុននឹងចូលក្នុងបន្ទប់បណ្តុះបណ្តាល ឬក្រោកឈរឡើង

**ច. ការប្រាស្រ័យទាក់ទង**

- ត្រូវមានការទាក់ទងតាមបែបពហុទិស ជៀសវាងសួរនាំដោយបែរមុខទៅណាផ្សេង
- អោយសិក្ខាកាមនិយាយអោយបានច្រើន ជៀសវាងនិយាយច្រើនជាងសិក្ខាកាម
- ពេលមានសំនួរពីសិក្ខាកាមណាម្នាក់ គួរអនុញ្ញាតអោយសិក្ខាកាមដ៏ទៃទៀតគេធ្វើការពន្យល់សាកល្បង បកស្រាយសិនមុននឹងពន្យល់ រឺបកស្រាយដល់សិក្ខាកាម ។

***ចំនុចសំខាន់ចុងក្រោយដែលគ្រូបណ្តុះបណ្តាលត្រូវប្រកាន់យកអោយបានខ្ជាប់ខ្ជួននោះ គឺត្រូវគោរពវិន័យសិក្ខាសាលាអោយបានល្អជាងសិក្ខាកាម ព្រមទាំងមានលក្ខណៈម៉ឺងម៉ាត់ និងហ្មត់ចត់ ។***

# ការរៀនសូត្ររបស់មនុស្សពេញវ័យ
# Adult Learning

ការរៀនសូត្រដែលមានលក្ខណៈចូលរួមមានលក្ខណៈល្អប្រសើរសំរាប់ការរៀនសូត្ររបស់មនុស្សពេញវ័យពីព្រោះ

- ចំណេះដឹង និងជំនាញ បានទៅដល់តំរូវការរបស់សិក្ខាកាម
- ផ្តល់នូវឱកាសក្នុងការចែករំលែកគំនិត បទពិសោធន៍ និងពតិមានទាំងឡាយតាមរយៈការពិភាក្សាដោយចំហរ
- ជួយគ្នាទៅវិញទៅមកក្នុងការរៀនសូត្រនៅក្នុងពេលបណ្តុះបណ្តាល និងក្រោយពេលបណ្តុះបណ្តាល
- កសាងទំនុកចិត្តក្នុងការផ្លាស់ប្តូរ

ជាការចាំបាច់ ដែលអ្នកសំរបសំរួលត្រូវដឹងពីរបៀបរៀនរបស់មនុស្សពេញវ័យ ដើម្បីងាយសំរបតាម និងយល់ច្បាស់ពីពួកគេ និងអាចទទួលជោគជ័យទៅតាមគោលបំណងដែលចង់បាន។

- **បើយល់ពីខ្លួនឯង មិនយល់ពីខ្មាំង ច្បាំង១០០ដង ឈ្នះ៥០ដង ចាញ់៥០ដង**
- **បើយល់ពីខ្មាំង មិនយល់ពីខ្លួនឯង ច្បាំង១០០ដង ឈ្នះ៥០ដង ចាញ់៥០ដង**
- **យល់ពីខ្មាំង យល់ពីខ្លួនឯង ច្បាំង១០០ដង ឈ្នះ១០០ដង ។**

ការអប់រំមនុស្សចាស់ក៏ដូចគ្នាដែរ មុននឹងទៅបង្រៀនសិស្ស ត្រូវយល់ពីខ្លួនឯងក្នុងនាមអ្នកសំរបសំរួល និងយល់ពីខ្មាំងក្នុងនាមជាសិស្ស ទើបធ្វើការបានជោគជ័យ។

## ១. ភាពខុសគ្នា នៃការរៀនរបស់កុមារ និងការរៀនរបស់មនុស្សចាស់ :

**- ការរៀនរបស់កុមារ :**

កុមារ មានវិធីរៀនខុសពីមនុស្សពេញវ័យ រឺមនុស្សចាស់ ព្រោះកុមារមានបទពិសោធន៍តិចតួច ដូចនេះពួកគេធ្វើតាមតែគេប្រាប់ប៉ុណ្ណោះ។ កុមារចងចាំ និងរៀនជំនាញថ្មីៗបានល្អប្រសើរ ប៉ុន្តែការផ្តោតអារម្មណ៏របស់កុមារមានរយៈពេលខ្លី។ កុមារទទួលយកចំណេះដឹងថ្មីដោយមិនចាំបាច់សួរនោះទេ។

**- ការរៀនរបស់មនុស្សចាស់**

មនុស្សធំមានបទពិសោធន៍ច្រើន។ ពួកគេចង់ដឹងពីមូលហេតុដែលពួកគេត្រូវធ្វើចង់រៀនពីអ្វីដែលខ្លួនយល់ថា មានប្រយោជន៏ចំពោះខ្លួន។ ពួកគេនឹងជំទាស់នូវយោបល់ដែលផ្ទុយពីជំនឿរបស់ពួកគេ និងផ្ទុយពីអ្វីដែលជាបទពិសោធន៍ដែលបានបង្រៀនពួកគេ។ មុខមាត់គឺជាបញ្ហាសំខាន់របស់មនុស្សធំ។ ពួកគេចង់អោយគេគោរព និងប្រាស្រ័យមករកខ្លួនអោយបានស្មើៗគ្នា។

## ☞ លក្ខណៈ និងការសំដែងចេញរបស់មនុស្សចាស់ :

- មានបទពិសោធន៏ដើមខុសៗគ្នា នាំអោយការយល់ដឹងមិនស្មើគ្នា
- គ្មានការទុកចិត្តខ្លួនឯង មិនហ៊ានបញ្ចេញគំនិត មិនចង់រៀន ព្រោះមិនចង់ឃើញផលប្រយោជន៏នៃការសិក្សា ប៉ុន្តែ

បើមានចំនុចពេញចិត្តចំសេចក្តីត្រូវការរបស់គេ នោះនឹងមានការចាប់អារម្មណ៍យ៉ាងខ្លាំង

- ចង់បានផលប្រយោជន៍ចំពោះមុខច្រើនជាងថ្ងៃអនាគត
- មិនចូលចិត្តការទិតៀន តែចូលចិត្តការលើកតំកើង និងសរសើរ
- មានភារកិច្ច និងកង្វល់ច្រើន ព្រោះខ្លួនត្រូវទទួលខុសត្រូវក្នុងជីវភាពរស់នៅ
- ចូលចិត្តធ្វើតាមទំលាប់ ហើយពិបាកក្នុងការផ្លាស់ប្តូរទស្សនៈ និងជំនឿដែលពួកគេធ្លាប់មាន
- មិនចូលចិត្តការប្រឡង តែចូលចិត្តអ្វីងាយស្រួលដែលខ្លួនចេះស្ទាត់
- ចូលចិត្តការពិតយុត្តិធម៌ និងមានហេតុផល
- មានសមត្ថភាពប្រើប្រាស់ភាសាបានតិច
- មានការខ្មាស់អៀន ហើយខ្លាចខុសជាងក្មេង
- មិនចូលចិត្តចូលរួមក្នុងអង្គប្រជុំ
- មិនចូលចិត្តអោយជួយទំនុកបំរុង និងយកចិត្តទុកដាក់ពេកទេ
- ស្គាល់តួនាទី និងភារកិច្ចរបស់ខ្លួន ស្គាល់ចំណេះដឹង និងសមត្ថភាពរបស់ខ្លួនក៏រិតណា

☞ **មនុស្សចាស់រៀនបានប្រសើរបំផុតនៅពេលដែល :**

- គេរៀនឆាប់ចេះ និងល្អិតល្អន់នៅពេលដែលពួកគេចង់រៀន មានន័យថានៅពេលដែលមានការលើកទឹកចិត្ត
- ទំនាក់ទំនងជិតស្និទ្ធរវាងសិក្ខាកាម និងគ្រូបណ្តុះបណ្តាល គឺជាការសំខាន់ណាស់
- ការរៀនសូត្រអាចមានភាពប្រសើរនៅពេលគ្មានបរិយាកាសរំខាន់
- គេចង់រៀនបើសិនខ្លឹមសារមេរៀនច្បាស់លាស់ ប្រើពាក្យ និងភាសាសាមញ្ញ មានរូបភាពជំនួយក្នុងការបង្ហាត់ និងមានឧទាហរណ៍ជាក់ស្តែង ។
- ប្រធានបទនៃការបណ្តុះបណ្តាលមានលក្ខណៈទាក់ទងទៅនឹងតំរូវការ និងផលប្រយោជន៍របសិក្ខាកាម
- សិក្ខាកាមរៀនបានប្រសើរនៅពេលដែលជំនាញទាក់ទងទៅនឹងអ្វីដែលពួកគេបានដឹង រឺអាចធ្វើបាន
- មនុស្សធំមានបទពិសោធន៍ ហើយបានរៀនច្រើនពីជីវិតពិត ។ គាត់ត្រូវបានលើកទឹកចិត្តដោយផ្លាស់ប្តូរនូវបទពិសោធន៍របស់ខ្លួន ។
- ការរៀនបានប្រសើរនៅពេលដែលពតិមាន រឺជំនាញត្រូវបានបង្រៀនតាមវិធីសមស្រប
- មនុស្សធំចង់បានសេចក្តីថ្លៃថ្នូរ និងចង់អោយគេគោរពគ្រប់ពេលវេលាទាំងអស់
- នៅពេលមនុស្សមានវ័យកាន់តែចំណាស់ ការចង់ចាំរបស់ពួកគេកាន់តែខ្សោយ ប៉ុន្តែសមត្ថភាពគេកាន់តែច្រើនក្នុងការសង្កេត និងផ្តល់ហេតុផល លើកនូវបញ្ហានានា ហើយលើកទឹកចិត្តអោយមានការពិភាក្សា និងផ្តល់យោបល់ ។

☞ **ជារួម មនុស្សចាស់រៀនបាន**

☺ **ប្រសើរបំផុត** : នៅពេលដែលគេធ្វើការស្រាវជ្រាវ និងស្វែងយល់ពីខ្លួនឯង

☺ **ល្អ** : ប្រសើនបើគេអនុវត្តន៍ផ្ទាល់

☺ **មធ្យម** : ប្រសិនបើគេរៀនដោយគ្រាន់តែស្តាប់ និងមើលតាមគេ

☺ **ខ្សោយ** : ប្រសិនបើរៀន ស្គាល់តាមគេ

## ២. វិធីសាស្ត្រ ដើម្បីជំរុញអោយអោយសិក្ខាកាម/អ្នកតូមិមានការចូលរួម :

- **ត្រូវមានភាពស្និទ្ធស្នាល និងមានភាពសាមញ្ញ :** មិនត្រូវធ្វើអោយដែលនាំអោយមានការចាប់អារម្មណ៍ថា អ្វីៗប្រព្រឹត្តិទៅក្នុងលក្ខណ:ជាផ្លូវការឡើយ ។ ការចាប់អារម្មណ៍បែបនេះ ធ្វើអោយអ្នកចូលរួមមានការភ័យខ្លាច អៀនខ្មាស និងមានភាពស្ងៀមស្ងាត់ ។
- **ការសួរសំណួរ :** សំណួរ គឺជាឧបករណ៍យ៉ាងសំខាន់របស់អ្នកសំរបសំរួល ក្នុងការជំរុញអោយអ្នកចូលរួមគិត និងពិចារណា ត្រូវរៀបចំសំណួរអោយមានលក្ខណ:សាមញ្ញ ហើយងាយយល់ ។
- **ការចាប់ផ្តើមទៅតាមកំរិតយល់ដឹងរបស់សិក្ខាកាម :** នៅពេលលើកយកប្រធានបទថ្មីមកពិភាក្សា ជាដំបូងត្រូវសួរអ្នកចូលរួមពីអ្វីដែលគាត់បានដឹងពីប្រធានបទនេះ រឺលើកពីបទពិសោធន៍ដែលគាត់មាន ។ ទង្វើបែបនេះ នឹងត្រូវផ្តល់ឱកាសអោយអ្នកសំរបសំរួលបានដឹងច្បាស់ថាតើអ្នកចូលរួមរបស់ខ្លួនមានចំណេះដឹងត្រឹមកំរិតណា ។
- **ត្រូវមានភាពអត់ធ្មត់ ហើយរង់ចាំចំលើយ:** អ្នកចូលរួម អាចត្រូវការពេលវេលាដើម្បីគិតពីសំណួររបស់អ្នកសំរបសំរួលមុននឹងអាចឆ្លើយបាន ។
- **បង្ហាញពីការចាប់អារម្មណ៍នូវអ្វីដែលអ្នកចូលរួមនិយាយ :** ការប្រើពាក្យថា "អូ ! ខ្ញុំយល់ហើយ" "សូមមានប្រសាសន៍បន្ថែមទៀត "អ្ហា"...គឺបង្ហាញថាអ្នកសំរបសំរួលមានការចាប់អារម្មណ៍ចំពោះអ្វីដែលអ្នកចូលរួមបានលើកឡើង ហើយជំរុញអោយអ្នកចូលរួមមានការក្លាហាននៅក្នុងការលើកឡើងបន្ថែមទៀត ។
- **ធ្វើអោយអ្នកចូលរួមគ្រប់រូប រួមចំណែកនៅក្នុងការពិភាក្សា :** នៅពេលសួរសំណួរ មិនត្រូវផ្តល់ការពេញចិត្តចំពោះចំលើយរបស់មនុស្សតែម្នាក់ទេ ។ អ្នកសំរបសំរួល ត្រូវធ្វើខ្លួនឯង និងអ្នកចូលរួមផ្សេងទៀតអោយមានការចាប់អារម្មណ៍ និងភ្ញាក់ផ្អើលចំពោះអ្វីដែលអ្នកផ្សេងបានលើកឡើង ។ ជំរុញអោយសិក្ខាកាមគ្រប់រូប និយាយ ប៉ុន្តែមិនត្រូវអោយអ្នកដែលមានវោហានិយាយលប់គេឯងឡើយ ។ ករណីខ្លះ អ្នកចូលរួមមិនហ៊ាននិយាយនៅក្នុងក្រុមធំ ដូច្នេះអ្នកសំរបសំរួលត្រូវចែកជាក្រុមតូចៗ (៣-៤នាក់) ដែលងាយស្រួលធ្វើអោយអ្នកចូលរួមដែលមានការអៀនខ្មាស ងាយស្រួល និងហ៊ានក្នុងការចូលរួមយោបល់ ។ ត្រូវព្យាយាមលើកអ្នកដែលមានសភាពស្ងៀមស្ងាត់ជាងគេ និងជំរុញអោយអ្នកទាំងនោះ មានភាពក្លាហាន និងហ៊ានចូលរួមបញ្ចេញយោបល់នៅក្នុងការពិភាក្សា ។ អ្នកសំរបសំរួលត្រូវលើកទឹកចិត្តចំពោះចំលើយ

ដែលលើកឡើងទាំងពីសិក្ខាកាមចាស់ និងក្មេង, ពីស្ត្រី និងបុរស, ពីអ្នកដែលមានអាជីពផ្សេងៗគ្នា រឺពីគណបក្សផ្សេងៗ ក្នុងករណីចាំបាច់ត្រូវធ្វើការបំបែកជាក្រុមតូចៗផ្សេងៗគ្នា ដែលនឹងផលប្រយោជន៍ច្រើននៅក្នុងការពិភាក្សា នៅពេលដែលពួកគេអាចស្ថិតនៅក្នុងក្រុមដែលមានវ័យ រឺស្ថានភាពដូចគ្នា ។

☛ **អ្នកសំរបសំរួលត្រូវរក្សាអោយបានជាប់ជានិច្ចនូវ ខ្សែភ្នែកមើលចំ ទៅសិក្ខាកាមទាំងបុរស និងស្ត្រី ដែលវាធ្វើអោយសិក្ខាកាមទាំងអស់មានអារម្មណ៍ថាខ្លួនគេត្រូវបានផ្តល់តំលៃអោយ ។ ដើម្បីលើកទឹកចិត្តអោយស្ត្រីមានភាពក្លាហានហ៊ានបញ្ចេញយោបល់នៅក្នុងក្រុមអ្នកសំរបសំរួលត្រូវធ្វើការបែងចែកអោយស្ត្រីបានស្ថិតនៅក្នុងក្រុមណាដែលគិតថាអាចមានភាពងាយស្រួលដល់កាចូលរួមនៅក្នុងក្រុម ហើយស្ត្រីគួរត្រូវបានផ្តល់កិត្តិយសដោយអញ្ជើញអោយមានការបញ្ចេញមតិយោបល់មុនគេ។ ក្នុងករណីចាំបាច់ខ្លះ អ្នកសំរបសំរួលអាចពិចារណាក្នុងការចែកជាក្រុមស្ត្រី និងក្រុមបុរសដាច់ដោយឡែកពីគ្នា។**

- **ធ្វើជាអ្នកអព្យាក្រិត និងមិនលំអៀង :** អ្នកសំរបសំរួលត្រូវដឹងថា សិក្ខាកាមអាចនឹងប្រកាន់នូវនិន្នាការនយោបាយរៀងៗខ្លួន ហេតុដូចនេះអ្នកសំរបសំរួលត្រូវធានាអោយប្រាកដថាខ្លួនមិនប្រកាន់នូវនិន្នាការនយោបាយណាមួយ ហើយធ្វើអោយមានការបំបាក់ទឹកចិត្តដល់សិក្ខាកាមដែលមាននិន្នាការផ្ទុយពីយើងឡើយ មានន័យថាអ្នកសំរបសំរួល ត្រូវធានានូវភាពស្មើគ្នាសំរាប់គ្រប់និន្នាការនយោបាយទាំងអស់ ។
- **ត្រូវពិនិត្យ និងស្វែងយល់អំពីអារម្មណ៍របស់សិក្ខាកាម :** ប្រសិនបើអ្នកសំរបសំរួលសង្កេតឃើញមានបរិយាកាសដែលសិក្ខាកាមមិនបានស្តាប់ រឺទទួលយកបានល្អពីការសំរបសំរួលរបស់ខ្លួន អ្នកសំរួលសំរួលត្រូវធ្វើការស្វែងយល់ជាបន្ទាន់ជាមួយពួកគេនូវអ្វីដែលជាបញ្ហា? អាចពួកគេត្រូវការសំរាក, អ្វីដែលផ្តល់អោយវាលឿនពេកសំរាប់ពួកគេ, អាចថាអ្វីដែលផ្តល់អោយមិនមានជាប់ពាក់ព័ន្ធជាមួយពួកគេ ។ល ។ អ្នកសំរបសំរួលត្រូវផ្តល់នូវការសំរាក ប្រសិនបើបរិយាកាស និងពេលវេលាតំរូវអោយ ។

**ត្រូវចងចាំថា អ្នកសំរបសំរួល គឺត្រូវជួយអោយអ្នកចូលរួមគិត ហើយស្វែងរកដំណោះស្រាយដោយខ្លួនឯង ដោយអ្នកសំរបសំរួលមិនត្រូវគិតជំនួស រឺប្រាប់ដល់អ្នកចូលរួមពីអ្វីដែលគាត់ត្រូវគិត និងអ្វីដែលគាត់ត្រូវធ្វើឡើយ ។**

## ៣. លក្ខណៈសម្បត្តិរបស់អ្នកសំរបសំរួល :

មនុស្សម្នាក់ដែលមានចំនេះដឹងច្រើន អាចធ្វើជាអ្នកសំរបសំរួល រឺអ្នកដឹកនាំបាន តែផ្ទុយមកវិញការធ្វើជាអ្នកដឹកនាំ រឺអ្នកសំរបសំរួលមិនសំដៅលើតែអ្នកមានចំណេះដឹងខ្ពស់នោះទេ ព្រោះវាអាស្រ័យលើជំនាញនៃការដឹកនាំ និងការសំរបសំរួលរបស់គេថាតើមានសមត្ថភាពអាចដោះស្រាយចំពោះបញ្ហានៅក្នុងសិក្ខាសាលាបានដែររឺអត់?

ដើម្បីទទួលបាននូវជំនាញសំរបសំរួលដ៏ពិតប្រាកដ និងជោគជ័យក្នុងអាជីពជាអ្នកសំរបសំរួលនោះ សិក្ខាកាមក្នុងវគ្គនេះ ( អ្នកដែលចង់ក្លាយជាអ្នកសំរបសំរួល) ត្រូវយកចិត្តទុកដាក់ និងកែលំអលក្ខណៈសម្បត្តិរបស់ខ្លួនអោយដូចខាងក្រោម :

- **ការជឿជាក់លើខ្លួនឯង និងការតាំងចិត្ត**

ត្រូវមានជំនឿទុកចិត្ត និងផ្តល់កំលាំងចិត្តដល់ខ្លួនឯងអោយមានជំហររឹងមាំថា អ្នកអាចដឹកនាំសិក្ខាសាលាបានក្នុងនាមអ្នក

ជាអ្នកសំរបសំរួល ។ អ្នកសំរបសំរួលជាអ្នករៀនម្នាក់ មិនមែនជាអ្នកបង្រៀនទេ ហើយក៏មិនមែនជាអ្នកចេះគ្រប់ដប់ដែរ ។

- **សំដែងទឹកចិត្តសោមនស្ស និងភាពជិតស្និទ្ធ**

អ្នកសំរបសំរួលត្រូវបង្ហាញភាពរីករាយរបស់ខ្លួនចំពោះអ្នកដទៃ និងចេះសំរបខ្លួនអោយបានជិតស្និទ្ធិជាមួយសិក្ខាកាម ។ ការបង្ហាញបែបនេះ ធ្វើអោយសិក្ខាកាមមានអារម្មណ៍ថា អ្នកសំរបសំរួល គឺជាសមាជិកម្នាក់ក្នុងក្រុមរបស់ពួកគាត់ ដែលអាចផ្តល់នូវភាពក្លាហានរបស់អ្នកចូលរួមអោយហ៊ានបញ្ចេញយោបល់កាន់តែស្វាហាប់ ។

- **បង្កើតបរិយាកាសរីករាយ និងចេះដើរតួច្រើនយ៉ាង**

អ្នកសំរបសំរួលត្រូវចេះលេងសើច តែមិនមែនជាតុ្លកកំប្លែងនោះទេ ។ ក្នុងពេលតែមួយ អាចដើរតួជាអ្នកសំរបសំរួលផង អ្នកស្តាប់ផង រៀនផង បង្រៀនផង ជាមិត្តផង ។

- **យកចិត្តទុកដាក់លើអារម្មណ៍សិក្ខាកាម**

អ្នកសំរបសំរួលត្រូវចេះសង្កេត និងឆាប់យល់ពីអារម្មណ៍របស់អ្នកចូលរួម ថាតើពួកគាត់មានអារម្មណ៍បែបណា? មានភាពរីករាយ មានការខឹង មានការធុញទ្រាន់ មានភាពរំជួលចិត្ត ពេញចិត្តក្នុងការពិភាក្សា និងចេះបត់បែននូវវិធីសាស្ត្រអោយស្របតាមអារម្មណ៍របស់សិក្ខាកាម ។

- **មានកាយវិការ ពាក្យសំដី ត្រឹមត្រូវសមស្រប និងទាក់ទាញ**

អ្នកសំរបសំរួលត្រូវចេះប្រើក្រសែភ្នែក ទឹកមុខស្រស់ថ្លា ឈរនិយាយបែរមុខទៅសិក្ខាកាម មានចលនាដៃ ជើង ដែលធ្វើអោយអ្នកចូលរួមចាប់អារម្មណ៍ និងមានការចូលចិត្តចំពោះកាយវិការទាំងនោះ ។ ការនិយាយស្តីរបស់អ្នកសំរបសំរួល ត្រូវច្បាស់ មិនញាប់ពេក មិនយឺតពេក និងចេះលើកដាក់សំលេង ។

- **ជំរុញអោយមានការបញ្ចេញមតិយោបល់ និងបើកចំហ នៅក្នុងការស្តាប់ និងទទួលយក**

ជំរុញ និងលើកទឹកចិត្តគ្រប់បែបយ៉ាង ដើម្បីអោយអ្នកចូលរួមហ៊ាននៅក្នុងការបញ្ចេញមតិ យោបល់ ការយល់ឃើញ និងបទពិសោធន៍របស់ពួកគេ ព្រមទាំងស្តាប់ និងទទួលយកនូវរឿងរ៉ាវទាំងឡាយដែលបានលើកឡើង ។

- ចេះប្រើប្រាស់នូវវិធីសាស្ត្រដ៏ច្រើននានា ដោយអោយស្របទៅតាមស្ថានភាពផ្សេងៗ ។

## ៤. លក្ខណៈសម្បត្តិដែលអ្នកសំរបសំរួល ត្រូវជៀសវាង :

- ប្រកាន់ឬកថា ជាអ្នកខ្ពង់ខ្ពស់ជាងគេ ចេះជាងគេ និងមានលក្ខណៈរើសអើង
- មានលក្ខណៈម៉ឺងម៉ាត់ បង្គាប់បញ្ជា ឆេវឆាវ និងស្តីបន្ទោស
- អាក្បកិរិយាច្រងេងច្រងាងក្នុងការអង្គុយ ការឈរ ការដើរ ការប្រើម្រាមដៃចង្អុលសិក្ខាកាម ការឈរនិយាយបែរមុខទៅក្តារខៀន
- ការរៀបចំខ្លួនមិនសមជាអ្នកសំរបសំរួល ដូចជាការតុបតែងខ្លួនហួសហេតុពេក
- បដិសេធមតិយោបល់របស់អ្នកចូលរួម និងបំបាក់ទឹកចិត្តអ្នកចូលរួម
- ធុញទ្រាន់ក្នុងការដោះស្រាយបញ្ហាដែលកើតមាន និងធ្វើសេចក្តីសំរេចចិត្តជំនួសអ្នកចូលរួម

- បញ្ចុះបញ្ចូលអោយអ្នកចូលរួមធ្វើទៅតាមគំនិតរបស់ខ្លួន
- មិនបានរៀបចំកិច្ចការមុននឹងទៅសំរបសំរួល

# ការសំរបសំរួល
# Facilitation

ការសំរបសំរួលមានអត្ថន័យទូលំទូលាយដែលប្រហែលជាអាចពន្យល់បានតាមរបៀបផ្សេងៗពីគ្នានៅក្នុងបែបខុសៗគ្នាដែរ។ អត្ថន័យនៃការសំរបសំរួល មិនមែនសំដៅចំពោះតែវគ្គបណ្តុះបណ្តាលតែមួយប៉ុណ្ណោះនោះទេ គឺប្រើប្រាស់បានទាំងនៅក្នុងការប្រជុំ សិក្ខាសាលា វេទិកាពិភាក្សា និងការងារជាមួយសហគមន៍ផងដែរ។ អ្នកសំរបសំរួល ត្រូវមានជំនាញសំរបសំរួលប្រកបដោយប្រសិទ្ធភាព ទើបអាចជំរុញអោយវគ្គបណ្តុះបណ្តាល ការប្រជុំ សិក្ខាសាលា វេទិកាពិភាក្សា និងការធ្វើការងារជាមួយសហគមន៍ អាចទទួលបានការចូលរួមយ៉ាងពេញលេញ និងសំរេចបាននូវ គោលដៅដែលអាចមានការពេញចិត្តពីអ្នកចូលរួម។

## ១. និយមន័យការសំរបសំរួល

មានអត្ថន័យជាច្រើន ដែលត្រូវបានផ្តល់សំរាប់យល់ពីពាក្យថា ការសំរបសំរួល ដែលយើងនឹងលើកឡើងជំរាបជូនដូចតទៅនេះ

- ការសំរបសំរួល គឺជាដំណើរសកម្មភាពមួយ ដើម្បីធានាអោយមានប្រសិទ្ធិភាព និងជោគជ័យ នៅក្នុងការប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល រឺវេទិកាផ្សេងៗ
- ការសំរបសំរួល គឺជាការអនុវត្តន៍នូវវិធីសាស្រ្ត របស់អ្នកទទួលខុសត្រូវ នៅក្នុងព្រឹត្តិការណ៍អ្វីមួយ អោយទទួលបានលទ្ធផល ទៅតាមការគ្រោងទុក ។
- ការសំរបសំរួល គឺជាដំណើរការមួយដែលគេធ្វើអោយអ្នកចូលរួមក្នុងអង្គប្រជុំ ឬសិក្ខាសាលាទាំងអស់ធ្វើដំណើរទៅរកគោលបំណងរួមមួយ ដែលកំនត់ដោយមិនប្រើរបៀបដឹកនាំផ្ទាល់ ឬណែនាំផ្ទាល់ឡើយ។

ប៉ុន្តែ យើងអាចប្រើប្រាស់នូវអត្ថន័យមួយដែលមានលក្ខណៈសាមញ្ញ និងមានលក្ខណៈគ្របដណ្តប់គ្រប់គ្រាន់ គឺ**ការសំរបសំរួល គឺជាការធ្វើអ្វីមួយអោយមានលក្ខណៈងាយស្រួល**។ យោងទៅលើអត្ថន័យនេះ យើងអាចអោយហៅ**អ្នកសំរបសំរួល គឺជាអ្នកដែលធ្វើអ្វីមួយអោយមានលក្ខណៈសាមញ្ញ ងាយស្រួល សំរាប់នរណាម្នាក់ រឺក្រុមណាមួយ**។ ការសំរបសំរួល ប្រព្រឹត្តទៅដោយមានអ្នកសំរបសំរួល និងអ្នកចូលរួម/សិក្ខាកាម។ ជារួមអ្នកសំរបសំរួល គឺមានតួនាទីក្នុងការទទួលខុសត្រូវ ដើម្បីធ្វើអោយសំរេចបាននូវគោលបំណងនៃវគ្គបណ្តុះបណ្តាល ការប្រជុំ សិក្ខាសាលា។ អ្នកសំរបសំរួលដែលជោគជ័យ គឺដំបូងបំផុតពួកគេត្រូវតែមានចំណេះដឹងយ៉ាងម៉ត់ចត់ និងវាងវៃទៅលើប្រធានបទ ដែលពួកគេត្រូវធ្វើការសំរបសំរួល។ ឧទាហរណ៍ខ្លះនៃការសំរបសំរួលៈ

**ក. ការសំរបសំរួលក្នុងវគ្គបណ្តុះបណ្តាល :** គឺអ្នកសំរបសំរួល អនុវត្តនូវវិធីសាស្រ្តនានា ដើម្បីអោយមានសិក្ខាកាមងាយស្រួលក្នុងការទទួលយកនូវចំណេះដឹង ដែលយើងត្រូវផ្តល់អោយគាត់ ហើយធានាថាសិក្ខាកាមនឹងមានលក្ខណៈងាយស្រួលនៅក្នុងការអនុវត្តន៍ចំនេះដឹងរបស់ខ្លួននៅក្រោយពីវគ្គបណ្តុះបណ្តាលត្រូវបានបញ្ចប់។

**ខ. ការសំរបសំរួលនៅក្នុងការងារអភិវឌ្ឍន៍សហគមន៍ :** គឺអ្នកសំរបសំរួល អនុវត្តនូវវិធីសាស្ត្រនានា ដើម្បីអោយសហគមន៍មានភាពងាយស្រួល នៅក្នុងការបង្កើនជីវភាពរស់នៅ និងជួយអោយការងារអភិវឌ្ឍន៍របស់គំរោងឆ្លើយតបទៅនឹងសេចក្តីត្រូវការពិតរបស់ប្រជាពលរដ្ឋ ក្នុងសហគមន៍។

**គ. ការសំរបសំរួលអង្គប្រជុំ :** គឺអ្នកសំរបសំរួល អនុវត្តវិធីសាស្ត្រនានា ដើម្បីអោយការប្រជុំមានដំណើរការទៅ ប្រកបដោយភាពរលូន និងសំរេចបាននូវលទ្ធផលជាវិជ្ជមានតាមរបៀបវីរៈដែលគ្រោងទុក។

មានកត្តាសំខាន់ពីរយ៉ាង ដែលអោយការសំរបសំរួល ប្រព្រឹត្តិទៅប្រកបដោយប្រសិទ្ធិភាព គឺ :

- ការផ្តល់ និងជំរុញអោយមានការបញ្ចេញមតិ យោបល់
- ការស្តាប់ និងទទួលយកនូវមតិ យោបល់ដែលបានលើកឡើង ( មិនប្រកាន់ថាមានតែគំនិតយោបល់របស់ខ្លួនឯងតែប៉ុណ្ណោះ ដែលត្រឹមត្រូវ និងល្អ) ។

☞ ***ការសំរបសំរួល គឺមិនសំដៅទៅលើបុគ្គលណាម្នាក់ (រឺក្រុមណាមួយ) ដាក់ការយល់ ឃើញរបស់ខ្លួនទៅលើអ្នកផ្សេងទៀតឡើយ។ ការសំរបសំរួល គឺសំដៅទៅលើសមត្ថភាពអាចណែនាំដំណើរការដែលអ្នកចូលរួមអាចបញ្ចេញមតិសេរី និងដោយសំងាត់អំពីស្ថានភាពផ្ទាល់ខ្លួន។***

**រូបភាពបង្ហាញពីប្រសិទ្ធិភាពផ្សេងៗគ្នា នៃការសំរបសំរួល ដែលប្រើប្រាស់វិធីសាស្ត្រផ្សេងៗ**



ខាងលើនេះ គឺជាទ្រឹស្តី និងការវិភាគរបស់លោក Johari ដែលយើងហៅថាវិធីសាស្ត្របង្អួចចូហារី[1] (The Johari’s window) គឺជាឧទាហរណ៍នៃឧបករណ៍មួយ ដែលធ្វើការបង្ហាញអំពីភាពចាំបាច់ ក្នុងការបង្កើតអោយមានការជឿទុកចិត្តគ្នា

ទៅវិញទៅមក និងការយល់គ្នារវាងអ្នកសំរបសំរួល និងអ្នកភូមិទាំងអស់។ បង្អួចទី១ (នៅខាងលើឆ្វេង ដៃ) គេហៅថាជាស្ថានភាព "**គ្មានដឹងអ្វីទាំងអស់**" ដែលអ្នកសំរបសំរួល និងអ្នកភូមិមិនបានស្គាល់គ្នាទៅវិញទៅមក ដូច្នេះមិនអាចចែករំលែកគំនិតរបស់ពួកគេអោយគ្នាទៅវិញទៅមកបាន។ បង្អួចទី២ (នៅខាងលើស្តាំដៃ) គឺជាស្ថានភាព " **ងងឹត** " ដែលអ្នកសំរបសំរួល អាចមើលឃើញអំពីបញ្ហានានា និងដំណោះស្រាយផ្សេងៗនៅក្នុងភូមិ ក៏ប៉ុន្តែអ្នកភូមិ មិនបានមើលឃើញអំពីបញ្ហា និងដំណោះស្រាយទាំងអស់នោះទេ។ បង្អួចទី៣ (នៅឆ្វេងដៃខាងក្រោម) មាន ន័យថាស្ថានភាព" **លាក់កំបាំង** " ដែលអ្នកភូមិមានគំនិតជាក់លាក់ អារម្មណ៍ជឿជាក់ ជំនឿ តំលៃ ការភ័យខ្លាច ។ល។ ដែលមិនបានដឹងដោយអ្នកសំរបសំរួល។ ស្ថានភាពទាំងនេះ បានលាក់កំបាំងពីការមើលឃើញរបស់អ្នកសំរបសំរួល។ បង្អួចចុងក្រោយ (នៅខាងក្រោមស្តាំដៃ) គឺជាស្ថានភាព" **បើកចំហ** " ដែលភាគីទាំងសងខាងស្គាល់គ្នាទៅវិញ ទៅមក ហើយមានការស្មោះស្ម័គ្រចំពោះការពិភាក្សាលើគំនិតរបស់ពួកគេ។

ហេតុដូច្នេះហើយ **ការសំរបសំរួលគឺមិនសំដៅទៅលើបុគ្គលណាម្នាក់ (ឬក្រុមរបស់បុគ្គលណាមួយ) ដាក់បង្ខំការយល់ឃើញរបស់ខ្លួនទៅលើអ្នកផ្សេងទៀតឡើយ។** ការសំរបសំរួល គឺសំដៅទៅលើសមត្ថភាពអាចណែនាំ ដល់ដំណើរការដែលអាចអោយអ្នកចូលរួមបញ្ចេញមតិដោយសេរី និងដោយសំងាត់អំពីស្ថានភាពផ្ទាល់របស់ខ្លួន។ នៅពេលមួយនោះអ្នកភូមិម្នាក់ បានប្រាប់អ្នកសំរបសំរួលម្នាក់ថា "***ប្រសិនបើលោក/លោកស្រីមកទីនេះ ដើម្បីបង្ហាញពួកយើងនូវរបៀបដោះស្រាយបញ្ហា ពួកយើងនោះលោក/លោកស្រី អាចចាកចេញពីទីនេះភ្លាម។ ប៉ុន្តែប្រសិនបើ លោក/លោកស្រីនៅទីនេះ ដើម្បីជួយពួកយើងអោយយល់អំពីរបៀបដែលយើងអាចដោះស្រាយបញ្ហារបស់ពួកយើងបាន នោះលោក/ លោកស្រី អាចនៅទីនេះដោយសេរី ហើយយើងសូមស្វាគមន៍លោក/លោកស្រីដោយស្មោះពីចិត្ត***" ។

នៅក្នុងការងារអភិវឌ្ឍន៍សហគមន៍ អ្នកសំរបសំរួល ត្រូវតែព្យាយាមបើកចំហរនូវបង្អួច នៅកន្លែងដែលបញ្ហារបស់សហគមន៍ ត្រូវបានពិភាក្សាអោយតំលៃទៅលើចំណេះដឹង និងបទពិសោធន៍នៅមូលដ្ឋាន។ អ្នកសំរបសំរួលមកពីខាងក្រៅមានជំនាញ និងចំណេះដឹង ដែលត្រូវការច្របាច់បញ្ចូលគ្នាជាមួយនឹងបទពិសោធន៍នៅមូលដ្ឋាន។

ប្រសិនបើអ្នកមកពីខាងក្រៅមិនព្យាយាមយល់ពីវប្បធម៌ សហគមន៍ បែបបទ យន្តការ ជំនឿ និងតំលៃ ដែលជាទូទៅមិនបានផ្សព្វផ្សាយអោយមានការដឹងឮដោយប្រជាពលរដ្ឋ ល្គឹកណាពួកគេមិនទាន់ទទួលបាននូវការជឿជាក់នោះ វានឹងមានការលំបាកណាស់ក្នុងការងារអភិវឌ្ឍន៍ សហគមន៍ប្រកបដោយភាពជោគជ័យ។

## ២. ***សារៈសំខាន់ នៃការសំរបសំរួល***

- ដើម្បីដឹកនាំការពិភាក្សា នៅក្នុងអង្គប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល ប្រព្រឹត្តិទៅតាមកម្មវិធីដែលបានគ្រោងទុក និងសំរេចបាននូវគោលបំណងដែលបានរៀបចំ
- ដើម្បីអោយដំណើរការនៅក្នុងអង្គប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល ដំណើរការទៅដោយរក្សាបាន និងយកចិត្តទុកដាក់ទៅប្រធានបទដែលបានលើកឡើង ។
- ដើម្បីជំរុញ និងលើកទឹកចិត្តអោយមានការចូលរួមយោបល់ច្រើនពីអ្នកចូលរួម

⊙ ដើម្បីបង្កើតបរិយាកាសនៅក្នុងអង្គប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល មានលក្ខណៈល្អប្រសើរ និងមានភាពសកម្មរស់រវើក ព្រមទាំងធ្វើការងារមានភាពជាក្រុម រវាងអ្នកសំរបសំរួល និងអ្នកចូលរួម ។

# ជំនាញសំខាន់ៗ ដែលអ្នកសំរបសំរួលត្រូវមាន
# The Importan Skills for Facilitators

ក្នុងនាមជាអ្នកសំរបសំរួលម្នាក់ ត្រូវយល់ និងចេះនូវជំនាញសំខាន់ៗមួយចំនួនដែលចាំបាច់ជាជំនួយខានមិនបាន ដើម្បីអោយដំណើរការសំរបសំរួលរបស់ខ្លួនទទួលបាននូវប្រសិទ្ធិភាព និងលទ្ធផលល្អ ។ ជំនាញសំខាន់ៗទាំងនោះមាន:

- ជំនាញក្នុងការសួរសំនួរ
- ជំនាញក្នុងការស្តាប់
- ជំនាញធ្វើការបង្ហាញ
- ជំនាញក្នុងការប្រាស្រ័យទំនាក់ទំនង

## ១. ជំនាញក្នុងការសួរសំនួរ :

ការសួរសំនួរល្អ គឺជាការងារមួយយ៉ាងសំខាន់របស់អ្នកសំរបសំរួល ។ ការប្រើប្រាស់សំនួរ គឺដើម្បីធ្វើអោយសិក្ខាកាមគិត និងនិយាយដើម្បីបំភ្លឺអ្វីដែលបានលើកឡើង និងដើម្បីអោយបានដឹងថាតើសិក្ខាកាមឯកភាពគ្នារទេ។ សំនួរធ្វើអោយវគ្គបណ្តុះបណ្តាល រីផ្សព្វផ្សាយប្រព្រឹត្តិទៅយ៉ាងផុសផុល។ សំនួរ គឺជាការសួរលើអ្វីដែលយើងចង់ដឹងអោយច្បាស់ ហើយក៏ជាជំនាញមួយដែលធ្វើអោយការទំនាក់ទំនង កាន់តែមានភាពស្វាហាប់។ នៅក្នុងសិក្ខាសាលា រឺ អង្គប្រជុំនានា មិនអាចជៀសផុតពីការចោទជាសំនួរនោះទេ ប៉ុន្តែអ្វីដែលសំខាន់នោះគឺជំនាញនៃការសួរ ថាតើអ្នកសួរចេះសួរសំនួរដែររឺទេ? តើការសួរនោះអាចទទួលបានដែររឺទេ?

### ☞ សារៈសំខាន់ការសួរសំនួរ :

សំនួរ គឺជាឧបករណ៍សំខាន់ ដែលប្រើប្រាស់នៅក្នុងការសំរបសំរួល ក្នុងគោលបំណងដើម្បី :

- អោយសមាជិកក្រុមទាំងអស់ចូលរួមគ្រប់ៗគ្នា
- ទាក់ទាញសមាជិកទាំងអស់ដែលអៀនប្រៀន ស្ងៀមស្ងាត់ អោយចូលរួមបញ្ចេញយោបល់
- ដាស់សតិអារម្មណ៍អោយគេភ្ញាក់ ហើយគិត
- បញ្ឈប់ការសន្ទនារឿងផ្ទាល់ខ្លួន ឬទប់ស្កាត់សិក្ខាកាមណាម្នាក់ដែលនិយាយច្រើនតែឯង
- ទាក់ទាញសិក្ខាកាមអោយនិយាយពីបទពិសោធន៍ និងចំណេះដឹងរបស់ពួកគេ
- បញ្ជាក់ថា តើសិក្ខាកាមទាំងអស់ច្បាស់ពីប្រធានបទនោះឬទេ?

### ☞ ប្រភេទ នៃសំនួរ :

យោងទៅតាមចំលើយដែលត្រូវឆ្លើយ សំនួរមានពីរប្រភេទ គឺសំនួរបើក និងសំនួរបិទ ហើយប្រភេទសំនួរនេះត្រូវបានគេប្រើយ៉ាងញឹកញាប់ នៅក្នុងការទំនាក់ទំនងនានា ។

- **សំនួរបើក (Open Question)** : ជាសំនួរដែលមានជំរើសច្រើនសំរាប់ឆ្លើយ ។ សំនួរបើក ជំរុញសិក្ខាកាម អោយគិត ហើយផ្តល់មតិរបស់គាត់ផ្ទាល់ ។ ជាទូទៅសំនួរបើក គឺជាប្រភេទសំនួរបែបបរិយាយ ។ ភាគច្រើន នៅក្នុងការសួរសំនួរបើក គេច្រើនចាប់ផ្តើមសួរដោយពាក្យ ***អ្នកណា អ្វី ពេលណា កន្លែងណា ហេតុអ្វី យ៉ាងដូចម្តេច បែបណា ?***

  **ឧទាហរណ៍សំណួរបើក :**

☛ តើអ្នកយល់យ៉ាងដូចម្តេចចំពោះបេសកកម្មរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងរួមចំណែកអភិវឌ្ឍន៍សង្គមកម្ពុជានាពេលបច្ចុប្បន្ន?

☛ តើអ្នកណា ដែលអ្នកយល់ថាអាចចូលរួមធ្វើអោយមានការលុបបំបាត់នូវអំពើពុករលួយដែលកំពុងកើតមាននៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន?

- **សំនួរបិទ (Close Question)** : ជាសំនួរដែលគ្មានជំរើសច្រើនសំរាប់ឆ្លើយក្រៅពី **បាទ/ចាស** ឬ **ទេ** និយាយរួម សំនួរបែបនេះធ្វើអោយសិក្ខាកាមផ្តល់ចំលើយតែមួយប៉ុណ្ណោះ និងមិនអនុញ្ញាតអោយមានការពិភាក្សា និងការវិភាគឡើយ ហេតុនេះការប្រើសំណួរប្រភេទនេះ មិនមែនជាការប្រសើរឡើយ ប្រសិនបើអ្នកសំរបសំរួលចង់ជំរុញអោយមានការពិភាក្សា ។

## ☞ របៀបប្រើសំនួរក្នុងវគ្គបណ្តុះបណ្តាល

**– សំនួរទូទៅ (General Question)**

- ប្រើប្រាស់សំរាប់សួរទៅក្រុមទាំងមូល ដើម្បីបំផុសអោយសមាជិកក្រុមទាំងអស់រិះរកចំលើយ
- សួរនៅពេលចាប់ផ្តើមសកម្មភាពសិក្ខាសាលា ( មានប្រសិទ្ធិភាព)

**– សំនួរផ្ទាល់ (Direct Question)**

- គឺសំរាប់សួរមនុស្សម្នាក់ចំៗ
- ប្រើសំរាប់ទាក់ទាញសមាជិកដែលអៀន ឬមិនហ៊ានចូលរួមយោបល់ អ្នកដែលបែកគំនិត ឬនិយាយចាកពីប្រធានបទ អ្នកដែលនិយាយច្រើនតែឯង រឺអ្នកដែលជជែកគ្នាមិនយកចិត្តទុកដាក់ស្តាប់អោយបែរមកក្នុងការពិភាក្សាក្រុមវិញ ។

**– សំនួរបង្វែរទិស (Re-directed Question)**

- អ្នកសំរបសំរួលបង្វែរសំនួរទៅកាន់សិក្ខាកាម អោយឆ្លើយជំនួស បន្ទាប់ពីសិក្ខាកាមម្នាក់បានសួរមកកាន់ខ្លួន
- ជំរុញអោយការពិភាក្សាកាន់តែផុសផុលរវាងអ្នកចូលរួម និងអ្នកចូលរួម ។

## ☞ គោលការណ៍នូវនៅក្នុងការសួរសំនួរ :

- សំនួរគួរតែខ្លី ងាយយល់ និងប្រើពាក្យសាមញ្ញ ។ ត្រូវជៀសវាងសួរសំណួរណាដែលវែង ហើយមានច្រើនចំនុចបញ្ចូលគ្នា ។ **ឧទាហរណ៍** តើអ្នកចូលចិត្តហូបមីទេ? ប្រសិនបើចូលចិត្ត តើមីអ្វីដែលអ្នកចូលចិត្ត?
- ហើយតើអ្នកចូលចិត្តហូបមីជាមួយសាច់អ្វី? ហើយចូលចិត្តនៅហូបភាគច្រើននៅពេលណា?

- សំនួរផ្ទាល់ គួរសួរទៅកាន់សិក្ខាកាមដែលយើងជ្រើសមិនចំពោះថាអ្នកណាទេ ហើយគួរប្រើសំនួរណាដែលយល់ថា សិក្ខាកាមអាចឆ្លើយបាន ដើម្បីជៀសវាងនូវការបំបាក់ទឹកចិត្តដល់អ្នកចូលរួម ។
- គួរសួរចោះៗ ម្តងម្នាក់ៗ ដើម្បីអោយគេបានចូលរួមទាំងអស់គ្នា

## ២. ជំនាញក្នុងការស្តាប់ :

ប្រសិទ្ធិភាពក្នុងការទំនាក់ទំនង និងការសំរបសំរួល គឺមិនគ្រាន់តែជាសមត្ថភាពក្នុងការជជែក ពិភាក្សា ការនិយាយ រឺការផ្តល់ការណែនាំច្បាស់លាស់នោះទេ ។ ការទំនាក់ទំនង និងការសំរបសំរួល គឺមានគោលដៅដូចគ្នា នេះគឺការផ្តល់ និងទទួលពតិមានអោយមានប្រសិទ្ធភាព ដែលលទ្ធផលទាំងនេះ ត្រូវពឹងផ្អែកលើជំនាញនៃការស្តាប់ គឺមានន័យថាមិនមែនស្តាប់គ្រាន់តែស្តាប់នោះទេ ។

អ្នកដឹកនាំ រឺអ្នកគ្រប់គ្រង ជារឿយៗដើរតួនាទីជា "អ្នកដោះស្រាយបញ្ហា" ប៉ុន្តែយើងមិនអាចផ្តល់នូវដំណោះស្រាយទាំងឡាយមុនពេលដែលយើងមិនទាន់ដឹងច្បាស់លាស់ថា អ្វីជាបញ្ហានោះទេ ។ ដូចនេះ ក្នុងនាមជាអ្នកដឹកនាំ គុណភាពសំខាន់ផ្ទាល់ខ្លួនដែលយើងចាំបាច់ត្រូវមាននោះ គឺសមត្ថភាពក្នុងការស្តាប់ ។ សូមកុំយល់ច្រឡំការស្តាប់ ជាមួយនឹងការលឺសូរ ។ ការលឺ គឺមិនតំរូវអោយមានអ្វីច្រើនក្រៅពីបទពិសោធន៍ផ្ទាល់ខ្លួនទេ ប៉ុន្តែការស្តាប់ គឺនៅពេលដែលយើងទទួលយកគំនិត ធ្វើការវាយតំលៃគំនិត ហើយបន្ទាប់មកអនុវត្តតាមអ្វីដែលយើងបានលឺ ។ ការក្លាយទៅអ្នកពូកែស្តាប់មួយរូប គឺយើងអាចបង្កើនសមត្ថភាពក្នុងការបញ្ចុះបញ្ចូលច្រើនដងថែមទៀត ។

ខាងក្រោមនេះ គឺជាចំនុចសំខាន់ៗមួយចំនួនដើម្បីបង្កើនប្រសិទ្ធិភាពនៅក្នុងការស្តាប់ :

### ☞ ការបើកចំហគំនិត :

ការបើកចំហគំនិត គឺមានន័យថាបើកចិត្តអោយទូលាយក្នុងការទទួលយកពតិមាន រឺស្តាប់ និងមិនធ្វើការវិនិច្ឆ័យជាមុននូវអ្វីដែលអ្នកដទៃបំរុងនឹងនិយាយឡើយ ។ ប្រសិនបើអ្នកស្តាប់បានល្អ អ្នកនឹងអាចនិយាយឡើងវិញនូវអ្វីដែលគេបាននិយាយរួចហើយ ជាងនេះទៅទៀតប្រសិនបើយើងអាចប្រែក្លាយការស្តាប់នេះអោយទៅជាទំលាប់របស់យើង នោះយើងនឹងអាចបង្កើនការចងចាំផងដែរ ។

- អ្នកស្តាប់ ត្រូវទុករឿងផ្ទាល់ខ្លួនមួយអន្លើ ហើយរង់ចាំរហូតដល់អ្នកនិយាយបានបញ្ចប់សព្វគ្រប់នូវទស្សនះរបស់គេ
- អ្នកស្តាប់ ត្រូវតាំងចិត្ត និងប្រាប់ខ្លួនឯងថា ខ្ញុំនឹងអោយត្រចៀករបស់ខ្ញុំស្តាប់ ហើយខួរក្បាលរបស់ខ្ញុំធ្វើការពិចារណា
- អ្នកស្តាប់ត្រូវជៀសវាងការប្រកែក រឺកាមិនយកចិត្តទុកដាក់លើសាររបស់អ្នកនិយាយ ប៉ុន្តែផ្តោតឱកាសល្អដើម្បីនិយាយកាត់ដោយចោទជាសំនួរដើម្បីបញ្ជាក់អោយច្បាស់ពីយោបល់ដែលបានលើកឡើង ។
- អ្នកស្តាប់ត្រូវគិតថា អ្នកដែលអ្នកកំពុងនិយាយ កំពុងផ្តល់អំណោយដល់យើង

### ☞ ការផ្តោតអារម្មណ៍ទៅលើអ្វីដែលគេកំពុងនិយាយ :

សូមចងចាំថា ការលឺ គឺជាសកម្មភាព អកម្ម រឺឯការស្តាប់ គឺជាសកម្មភាពសកម្ម ។

- អ្នកស្តាប់អាចអង្គុយ រឺឈរនៅខាងមុខអ្នកនិយាយ ដើម្បីបង្ហាញថាអ្នកមានការចាប់អារម្មណ៍ទៅលើអ្វីដែលគេបាននិយាយ និងមិនមើលងាយគាត់ ។
- ប្រើភាសាកាយវិការ រឺសញ្ញាខ្លីៗ ដើម្បីបង្ហាញថា អ្នកកំពុងតែស្តាប់យ៉ាងយកចិត្តទុកដាក់ ដូចជាការមើលមុខអ្នកនិយាយដោយក្រសែភ្នែកប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ (ប៉ុន្តែមិនត្រូវសំលឹងយូរពេកទេ), រឺការងក់ក្បាល ការបន្លឺសំលេងថា "ខ្ញុំយល់ហើយ" "មែនហើយ" "គួរអោយចាប់អារម្មណ៍" ។ល។

☞ **ការលើកទឹកចិត្តអោយគេនិយាយ :**

អ្នកសំរបសំរួល ត្រូវចងចាំថា ការឆ្លើយតបទៅនឹងអ្នកនិយាយ គឺជាការលើកទឹកចិត្តអោយគាត់ចង់និយាយបន្តទៀត ។ ដូច្នេះ តួនាទីសំខាន់របស់អ្នកស្តាប់ គឺលទ្ធភាពនៅក្នុងការផ្តល់នូវការឆ្លើយតបទៅអ្នកនិយាយ ។

- លើកទឹកចិត្ត ប្រសើរជាងការបង្អាក់ទឹកចិត្ត ហើយត្រូវផ្តល់ពេលវេលាគ្រប់គ្រាន់ដល់អ្នកនិយាយក្នុងបរិយាកាសមួយដ៏ល្អ
- ទទួលស្គាល់ថារាល់បញ្ហាទាំងអស់ គឺសុទ្ធតែសំខាន់
- ជៀសវាងការកាច់បំបាក់អ្នកនិយាយ
- ជៀសវាងការលើកយកបញ្ហាផ្សេងមកឡូកឡំ ក្នុងអំឡុងពេលសន្ទនា
- ចោទជាសំនួរនៅពេលណាដែលសមរម្យ ដើម្បីអោយយល់ច្បាស់នូវរាល់ចំងល់ទាំងឡាយ
- សង្ខេបករណីដែលទើបនិយាយ រឺនិយាយឡើងវិញនូវពាក្យចុងក្រោយមួយចំនួន ដែលអ្នកនិយាយបានលើកឡើង

☞ **ប្រការសំខាន់មួយចំនួន ដែលត្រូវជៀសវាងនៅក្នុងការស្តាប់ :**

- ផ្តល់ការណែនាំ រឺនិយាយកាត់ (ដោយឆាប់ពេក) ក្នុងពេលដែលអ្នកដទៃគេកំពុងនិយាយ
- ធ្វើការប្រកែក រឺបង្ហាញពីការមិនយល់ព្រម ចំពោះយោបល់ដែលកំពុងលើកឡើង
- គិតរឿងផ្សេងៗ អាន រឺមើលសៀវភៅ រូបភាព ក្នុងពេលកំពុងស្តាប់អ្នកនិយាយ
- ការពេបមាត់ រឺបង្ហាញអាការៈថាអ្នកនិយាយមិនស្មើនឹងខ្លួន
- ចោលក្រសែភ្នែកសំលឹងទៅឆ្ងាយ (មិនយកចិត្តទុកដាក់ស្តាប់) កេះក្រចក ត្រចៀក ដៃ ។ល។
- ចោទជាសំនួរដើម្បីផ្ចាញ់ និងធ្វើការផ្តល់នូវការណែនាំ ផ្សេងៗ
- និយាយ រឺខ្សឹបខ្សៀវជាមួយអ្នកដទៃ (រឿងក្រៅពិភាក្សា)

☞ **ការស្តាប់ដែលមានការឆ្លុះបញ្ចាំង :**

ការស្តាប់ដោយមានការឆ្លុះបញ្ចាំង គឺជាជំនាញមួយដែលគេបង្ហាញអោយឃើញពីការយល់ព្រម និងបង្កើនជំនឿទុកចិត្តគ្នាទៅវិញទៅមក ។ វាបង្កើតអោយមានបរិយាកាសទាក់ទងគ្នាដោយចំហសំរាប់ការយល់ដឹង ។ អ្នកស្តាប់អាចរៀនគិតមើលពីអ្វីដែលមនុស្សម្នាក់ចង់បញ្ជាក់ និងពីប្រការដែលគេយល់ឃើញទៅលើស្ថានភាព និងបញ្ហាផ្សេងៗ ។ ការប្រើប្រាស់ការស្តាប់ដែលមានការឆ្លុះបញ្ចាំងបានសមស្រប អាចបង្កើនប្រសិទ្ធិភាពប្រាស្រ័យទាក់ទង និងអាចសំរួល ដល់ការដោះស្រាយបញ្ហា ។

☞ **វិធីសាស្ត្រផ្សេងៗក្នុងការ ស្តាប់ដោយមានការឆ្លុះបញ្ចាំងត្រលប់មកវិញ**

- **ការប្រាប់ឡើងវិញ** : ប្រាប់តាមអ្នកផ្តល់ពត៌មានអោយបានច្រើនតាមតែអាចធ្វើបាន
- **ការរៀបរាប់ឡើងវិញ** : រៀបរាប់ឡើងវិញពីអ្វីដែលអ្នកផ្តល់ពត៌មានបានប្រាប់
- **ការសង្ខេបឡើងវិញ** : សង្ខេបនូវចំនុចសំខាន់ៗចេញពីអ្វីដែលអ្នកផ្តល់ពត៌មានបានផ្តល់អោយ
- **ការឆ្លុះបញ្ចាំងពីអារម្មណ៍** : បង្ហាញថាពីការយល់ឃើញរបស់ខ្លួនចំពោះអ្នកផ្តល់ពត៌មាន
- **ការសួរបញ្ជាក់** : បញ្ជាក់នូវអ្វីដែលអ្នកផ្តល់ពត៌មានបានផ្តល់អោយ

## ៣. ជំនាញធ្វើការបង្ហាញ :

ដើម្បីអោយការសំរបសំរួល មានប្រសិទ្ធិភាពល្អ ការធ្វើបង្ហាញរបស់អ្នកសំរបសំរួល គឺជាកត្តាចាំបាច់បំផុត ដែលត្រូវអនុវត្ត។ ខាងក្រោមនេះ គឺជារបៀបធ្វើការបង្ហាញដែលមានប្រសិទ្ធិភាព :

- និយាយអោយយឺត លឺច្បាស់ ចំៗ ខ្លី ជៀសវាងការនិយាយច្រើនដែលមិនចំន័យសំខាន់ ដើម្បីអោយសិក្ខាកាមអាចតាមដានអ្វីដែលលោក-អ្នកកំពុងលើកឡើង
- ព្យួរក្រដាសទៅនឹងជញ្ជាំងក្តាខៀន ហើយអ្នកបង្ហាញឈរពីម្ខាងនៃក្រដាស ដោយបែរមុខទៅរកសិក្ខាកាមទាំងអស់ ជៀសវាងការបាំងមុខ
- គូសពីក្រោមបន្ទាត់ឬអក្សរណាមួយប្រសិនបើចង់សង្កត់ន័យ
- ប្រសិនបើលោក-អ្នក ត្រូវប្រើប្រាស់ក្តារខៀន រឺផ្ទាំងក្រដាស ដើម្បីសរសេរចំនុចសំខាន់ៗ ត្រូវសង្ខេបឃ្លាប្រយោគរបស់លោក-អ្នក ពីព្រោះការសរសេរឃ្លាប្រយោគវែង នឹងត្រូវប្រើផ្ទៃសំរាប់សរសេរច្រើន និងពេលវេលាយូរ។ ការសរសេរ ត្រូវអោយធំ ច្បាស់ ងាយយល់ និងស្រួលអាន ព្រមទាំងប្រើពណ៌ណា ដែលផិតខ្លាំងដូចជា ពណ៌ខ្មៅ ខៀវ ក្រហម បៃតង សំរាប់ការសរសេរ និងប្រើពណ៌លឿង ស្វាយ ទឹកក្រូច ស្ទើង និងពណ៌ផ្កាឈូកជាការសំគាល់ (ហាយឡាយ) និងត្រូវប្រើពណ៌ផ្សេងៗគ្នានៅក្នុងក្រដាសមួយសន្លឹក។
- ប្រើបន្ទាត់ ឬ ពិលពណ៌ដើម្បីចង្អុលបង្ហាញ
- អ្នកបង្ហាញមិនត្រូវអានអក្សរលើផ្ទាំងក្រដាស ទាំងអស់ដូចការអានមេរៀនទេ
- នៅពេលឆ្លងពីមេរៀនមួយទៅមេរៀនមួយទៀត ត្រូវបង្ហាញពីមេរៀនទំនាក់ទំនងរវាងមេរៀនចាស់ ជាមួយមេរៀនថ្មី ដើម្បីអោយសិក្ខាកាម គិតពីភាពស្របគ្នា នៃមេរៀនទាំងនោះ។
- នៅពេលបញ្ចប់មេរៀន ត្រូវសង្ខេបចំនុចសំខាន់ៗ ។ ជៀសវាងការលើកឡើងពីគំនិតថ្មីនៅពេលសង្ខេបមេរៀន

## ៤. ជំនាញក្នុងការប្រាស្រ័យទំនាក់ទំនង :

មនុស្សមិនអាចរស់នៅក្នុងសង្គមតែម្នាក់ឯងទេ ទោះជានៅក្នុងក្រុមតូច រឺក្រុមមនុស្សយ៉ាងច្រើនក៏ដោយក៏ត្រូវតែមានការទំនាក់ទំនងគ្នាដែរ ។ តើអ្វីទៅជាការទំនាក់ទំនង? តើការទំនាក់ទំនងមានឥទ្ធិពលអ្វីនៅក្នុងជំនាញសំរបសំរួល?

នៅក្នុងការទំនាក់ទំនង មានដៃគូពីរសំខាន់ នោះគឺម្នាក់ជា**អ្នកផ្តល់ពតិមាន និងម្នាក់ទៀតជាអ្នកទទួលពតិមាន** ។ **ការទំនាក់ទំនងមានប្រសិទ្ធភាព អាស្រ័យលើអ្នកបញ្ជូនពតិមានបានល្អ និងអ្នកទទួលបានច្បាស់** ។ ការទំនាក់ទំនង មានសារៈសំខាន់ណាស់ ឬអាចនិយាយបានថាការទំនាក់ទំនង គឺជាបច្ចេកទេសល្អមួយ និងមិនអាចអត់បានក្នុងជំនាញសំរបសំរួលប្រកបដោយជោគជ័យ ។

### ☞ និយមន័យការទំនាក់ទំនង

ការទំនាក់ទំនង គឺជាការផ្ទេរនូវការយល់ដឹងអោយគ្នាទៅវិញទៅមក ។ ការទំនាក់ទំនង គឺជាដំណើរការនៃការផ្តល់ និងទទួលពតិមាន ។ ការទំនាក់ទំនង គឺជាដំណើរការនៃការផ្តល់ពតិមានទៅអោយអ្នកស្តាប់ និងធ្វើអោយអ្នកស្តាប់យល់ដឹងពីគំនិត និងអក្បកិរិយារបស់ខ្លួន ។

– **អ្នកបញ្ជូនពតិមាន :** ជាអ្នកផ្តល់ពតិមាន រឺធ្វើការទំនាក់ទំនងជាមួយអ្នកស្តាប់ណាម្នាក់ដែលយើងចង់បញ្ជូន

– **អ្នកទទួលពតិមាន :** ជាអ្នកស្តាប់នូវពតិមានដែលបញ្ជូនដោយអ្នកដែលមានទំនាក់ទំនងជាមួយ

### ☞ របៀប នៃការធ្វើទំនាក់ទំនង

- តាមរយៈការនិយាយស្តី និងការស្តាប់
- តាមរយៈការសរសេរ និងការអាន
- តាមរយៈការប្រើប្រាស់សញ្ញាជំនួយ និងការមើលសញ្ញា

គ្រប់រូបភាពនៃការទំនាក់ទំនង ត្រូវតែមានអ្នកផ្តល់ និងអ្នកទទួលពតិមាន ហើយដំណើរការទទួលបានជោគជ័យ លុះណាតែពតិមានដែលផ្តល់ទៅពិត ហើយអ្នកស្តាប់បានច្បាស់គ្រប់ទាំងអស់ ។




### ☞ វិធីសាស្ត្រដើម្បីបង្កើនទំនាក់ទំនងល្អ

នៅក្នុងវិធីសាស្ត្រនេះ ផ្តោតសំខាន់លើអ្នកទំនាក់ទំនង អ្នកទទួលការទំនាក់ទំនង និងពតិមាន ។

✔ **អ្នកទំនាក់ទំនង រឺអ្នកបញ្ជូនពត៌មាន :**

- ត្រូវដឹងពីគោលបំណងរបស់ខ្លួនក្នុងការបញ្ជូនពត៌មាននោះ
- ពូកែស្តាប់ និងស្គាល់ពីការចាប់អារម្មណ៍លើអ្នកដែលយើងធ្វើការទំនាក់ទំនង
- គោរពអ្នកដែលយើងធ្វើការទំនាក់ទំនងជាមួយ
- ត្រូវដឹងពីវប្បធម៌ ភាសា និងទស្សនៈរបស់អ្នកដែលយើងទាក់ទង
- ត្រូវគិតពីពាក្យសំដីដែលត្រូវប្រើប្រាស់
- យល់ដឹងពីពត៌មានដែលត្រូវប្រើប្រាស់
- បង្កើតសញ្ញាជំនួសផ្សេងៗ ដែលងាយយល់ និងងាយទាក់ទង
- ព្យាយាមធ្វើយ៉ាងណាកុំអោយមានសំលេងរំខានដល់បរិយាកាសពិភាក្សា
- សួរឡើងវិញនូវកំរិតយល់ដឹងរបស់អ្នកទទួលពត៌មាន និងស្នើសុំយោបល់ពីអ្នកទទួលពត៌មាន

✔ **ពត៌មាន :**

- ជាពត៌មានពិត មានលក្ខណៈសាមញ្ញ ច្បាស់លាស់ និងមានប្រយោជន៍
- អាចឆ្លើយតបនឹងសេចក្តីត្រូវការរបស់អ្នកដែលយើងទាក់ទង

✔ **អ្នកស្តាប់ រឺអ្នកទទួលពត៌មាន :**

- ស្តាប់ដោយមានការឆ្លុះបញ្ចាំងត្រលប់មកវិញ ( បង្ហាញថាយល់ និងចាប់បានពីពត៌មាននោះបានត្រឹមត្រូវ)
- អ្នកទទួលពត៌មាន ច្បាស់ក្នុងការទទួល ដែលនាំអោយការទំនាក់ទំនងកាន់តែមានប្រសិទ្ធភាព
- មានចំណង់ដឹងពីពត៌មាននោះ បើកទូលាយទទួលយកនូវគំនិតថ្មី និងហ៊ានទទួលយកការពិត ។

☞ ***លក្ខណៈ រឺកត្តាដែលរារាំងដល់ជោគជ័យនៃការទំនាក់ទំនង***

☹ អ្នកស្តាប់គ្មានការចាប់អារម្មណ៍ ( ស្តាប់ គឺគ្រាន់តែស្តាប់)

☹ អ្នកស្តាប់សំដែងនូវភាពធុញទ្រាន់ រឺមិនចង់ស្តាប់

☹ មានសំលេងផ្សេងៗមករំខាន និងពេលវេលាមិនគ្រប់គ្រាន់

☹ ភាសារបស់អ្នកផ្តល់ពត៌មានពិបាកស្តាប់

☹ ភាពខុសគ្នាផ្នែកវប្បធម៌ ទស្សនៈ អត្តចរិក ភេទ

☹ មានពត៌មានច្រើនផ្តល់ក្នុងពេលតែមួយ

☹ ពុំមានការលើកទឹកចិត្តដល់ការទំនាក់ទំនង

☹ មានការអាក់អន់ចិត្ត និងមិនយល់ចិត្តគ្នា

## ☞ ការទំនាក់ទំនងនៅក្នុងជំនាញសំរបសំរួល

ការទំនាក់ទំនង គឺមានសារៈសំខាន់ណាស់ រឺអាចនិយាយបានថាការទំនាក់ទំនងជាបច្ចេកទេសល្អមួយ និងមិនអាចអត់បានក្នុងជំនាញសំរបសំរួលប្រកបដោយជោគជ័យ។

នៅក្នុងដំណើរការដំបូងនៃសិក្ខាសាលា រឺអង្គប្រជុំ រហូតដល់បញ្ចប់ គឺត្រូវការធ្វើទំនាក់ទំនងរវាងអ្នកចូលរួម និងអ្នកសំរបសំរួល អ្នកសំរបសំរួល និងអ្នកសំរបសំរួល អ្នកចូលរួម និងអ្នកចូលរួម។ ដំណើរការសិក្ខាសាលា នឹងមិនទទួលជោគជ័យទេ បើការទំនាក់ទំនង រឺការពិភាក្សាមិនទទួលបានការយកចិត្តទុកដាក់ពីអ្នកសំរបសំរួល និងអ្នកចូលរួម។ អ្នកសំរបសំរួល និងអ្នកចូលរួម ជាអ្នកផ្តល់ពត៌មានផង និងជាអ្នកទទួលពត៌មានផង។

# ការវាយតំលៃវគ្គបណ្តុះបណ្តាល
# Training Evaluation

ការវាយតំលៃវគ្គបណ្តុះបណ្តាល គឺដើម្បីចង់ដឹងអំពីគុណភាព និងប្រសិទ្ធិភាពនៃវគ្គបណ្តុះបណ្តាល ថាតើវាទទួលបានកំរិតណា ល្អ មធ្យម និងខ្សោយ។ តាមរយៈការវាយតំលៃ យើងនឹងដឹងថាតើវគ្គបណ្តុះបណ្តាលនោះបានសំរេចតាមគោលបំណងដែររឺទេ?

## ១. ប្រភេទ នៃការវាយតំលៃ

**តើគេធ្វើការវាយតំលៃវគ្គបណ្តុះបណ្តាលនៅពេលណាខ្លះ?**

- ការវាយតំលៃនៅមុនពេលវគ្គបណ្តុះបណ្តាលចាប់ផ្តើម
- ការវាយតំលៃពេលកំពុងអនុវត្តវគ្គបណ្តុះបណ្តាល
- ការវាយតំលៃបញ្ចប់វគ្គបណ្តុះបណ្តាល
- ការវាយតំលៃនៅក្រោយពេលបញ្ចប់វគ្គបណ្តុះបណ្តាល

## ២. ចំនុចដែលត្រូវធ្វើការវាយតំលៃ

**ការវាយតំលៃនៅក្នុងវគ្គបណ្តុះបណ្តាលមួយ គឺផ្តោតទៅលើចំនុចសំខាន់ៗដូចខាងក្រោម :**

- ចំណេះដឹងរបស់សិក្ខាកាមមុន និងក្រោយពេលវគ្គបណ្តុះបណ្តាល
- វិធីសាស្រ្ត និងសំភារៈបណ្តុះបណ្តាល
- ជំនាញអ្នកសំរបសំរួល
- ខ្លឹមសារមេរៀន
- ការរៀបចំចាត់ចែង និងបរិយាកាសក្នុងពេលបណ្តុះបណ្តាល
- ទំនាក់ទំនងរវាងអ្នកសំរបសំរួលជាមួយសិក្ខាកាម
- ជំនាញដែលសិក្ខាកាមទទួលបាន
- ការផ្លាស់ប្តូរអាកប្បកិរិយា និងអំពើប្រព្រឹត្តិ
- ចំនុចល្អ និងចំនុចកែលំអ យោបល់ និងសំណូមពរផ្សេងៗ

## ៣. ការវាយតំលៃមុនវគ្គបណ្តុះបណ្តាល :

- ដើម្បីដឹងពីចំណេះដឹង និងជំនាញ អាកប្បកិរិយា និងដឹងពីសេចក្តីត្រូវការរបស់អ្នកសិក្សាមុនពេលបណ្តុះបណ្តាល
- ដើម្បីរៀបចំផែនការបណ្តុះបណ្តាលអោយស្របទៅនឹងប្រភេទ និងកំរិតយល់ដឹងរបស់សិក្ខាកាម
- ដើម្បីរកសន្ទស្សន៍សំរាប់ធ្វើការវាយតំលៃនៅចុងក្រោយ

## ៤. ការវាយតំលៃពេលកំពុងអនុវត្តវគ្គបណ្តុះបណ្តាល :

- ដើម្បីរកអោយឃើញថា តើគោលបំណងមេរៀន រឺប្រធានបទដែលកំពុងបណ្តុះបណ្តាលបានសំរេចដែររឺទេ
- ដឹងពីចំនុចល្អ និងចំនុចដែលត្រូវកែលំអ យោបល់ សំណូមពរផ្សេងៗ
- កែលំអនូវចំនុចខ្វះខាត រឺបំពេញនូវសំណូមពរនានាដែលអាចធ្វើទៅបាន
- តើសិក្ខាកាមពេញចិត្តចំពោះវគ្គបណ្តុះបណ្តាលនេះដែររឺទេ

## ៥. ការវាយតំលៃពេលបញ្ចប់វគ្គបណ្តុះបណ្តាល :

- ដើម្បីវាស់ចំណេះដឹងរបស់សិក្ខាកាមនៅពេលបញ្ចប់វគ្គ
- ដើម្បីរកអោយឃើញថា តើលទ្ធផលដែលទទួលបាននោះសមស្របនឹងគោលបំណងរបស់វគ្គបណ្តុះបណ្តាលដែររឺទេ
- ដើម្បីរកអោយឃើញតើចំនុចអ្វីខ្លះ ដែលត្រូវកែលំអ និងបំពេញបន្ថែមសំរាប់វគ្គបណ្តុះបណ្តាលក្រោយទៀត

## ៦. ការវាយតំលៃនៅក្រោយពេលបញ្ចប់វគ្គបណ្តុះបណ្តាល :

- ដើម្បីរកអោយឃើញនូវលទ្ធផល ការផ្លាស់ប្តូរចំណេះដឹង ជំនាញ និងអាកប្បកិរិយា
- ដើម្បីរកនូវផលប៉ះពាល់ (Impact)

## ៧. វិធីសាស្រ្តវាយតំលៃ

**តើត្រូវធ្វើការវាយតំលៃវគ្គបណ្តុះបណ្តាលយ៉ាងដូចម្តេច?**

- ចែកទម្រង់វាយតំលៃអោយបំពេញ
- សំណួរ ចំលើយ
- ធ្វើលំហាត់
- ការធ្វើសំភាសន៍

## ៨. ពាក្យគន្លឹះនៅក្នុងការវាយតំលៃ

### ក. លទ្ធផលដែលទទួលបានពីវគ្គបណ្តុះបណ្តាល (Result Immediate or Output)

គឺជាជំនាញ ចំនេះដឹង អាកប្បកិរិយា និងឥរិយាបថដែលសិក្ខាកាមទទួលបានពីវគ្គបណ្តុះបណ្តាល ហើយសិក្ខាកាមនឹងត្រូវយកចំណេះដឹងរបស់ពួកគេទាំងអស់ទៅអនុវត្តជាក់ស្តែង។

### ខ. លទ្ធផលរបស់វគ្គបណ្តុះបណ្តាល (Outcome)

គឺជាសកម្មភាពរបស់សិក្ខាកាម ក្នុងការអនុវត្តតាមនូវអ្វីដែលគេបានទទួលពីវគ្គបណ្តុះបណ្តាលកន្លងមក (Action

Plan）។

**គ. ផលប៉ះពាល់** (Immediate/Effect/Impact)

វាគឺជាការផ្លាស់ប្តូរដែលកើតមានឡើងក្នុងស្ថានភាពណាមួយ បន្ទាប់ពីការអនុវត្តជាក់ស្តែងដោយជោគជ័យ ក្រោយពេលដែលបានបណ្តុះបណ្តាលចប់ ។

## ៩. ឧទាហរណ៍គំរូអំពីបញ្ជីសំណួរសំរាប់វាយតំលៃ

### ក. សំនួរសាកល្បងមុនពេលបណ្តុះបណ្តាលស្តីពីវគ្គគ្រូបណ្តុះបណ្តាល

**ឈ្មោះ.......................................ភេទ.........អាយុ...........            ស្ថាប័ន...............................................................**

**ទីលំនៅបច្ចុប្បន្ន....................................................................................................................................**

**ពិន្ទុសរុប :.......................ភាគរយ :............ចំនាត់ថ្នាក់ :......................................................................**

១. ចូរពន្យល់ពីពាក្យគន្លឹះទាំងបី ដែលជាមូលដ្ឋាននៅក្នុងការប៉ាន់ប្រមាណតម្រូវការបណ្តុះបណ្តាល? (១០ពិន្ទុ)

"អ្នកណាត្រូវការអ្វី ហើយអ្វី នោះត្រូវផ្តល់ដោយអ្នកណា?"

☐ អ្នកណាទី១, មានន័យយ៉ាងដូចម្តេច?..........................................................................................

☐ អ្វីទាំងនោះ, មានន័យយ៉ាងដូចម្តេច?..........................................................................................

☐ អ្នកណាទី២,មានន័យយ៉ាងដូចម្តេច?..........................................................................................

២. ចូររៀបរាប់ពីវិធីសាស្ត្រសំខាន់ៗ ដើម្បីធ្វើការប៉ាន់ប្រមានតម្រូវការវគ្គបណ្តុះបណ្តាល (១០ពិន្ទុ):

.............................................................................................................................................

.............................................................................................................................

...................................................................................................................................

៣. ចូរប្រាប់ពីពាក្យដែលមានន័យអាចវាស់វែង និងអាចប្រើប្រាស់សំរាប់សរសេរគោលបំណងវគ្គបណ្តុះបណ្តាល អោយបានយ៉ាងហោចណាស់៥ពាក្យ រួមជាមួយនឹងការអោយឧទាហរណ៏ (១០ពិន្ទុ):

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៤. ចូររៀបរាប់ពីវិធីសាស្ត្របណ្តុះបណ្តាល អោយបានចំនួន ៨ វិធីសាស្ត្រផ្សេងៗគ្នា ? (៥ពិន្ទុ)

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៥. ចូរលើកឡើងអំពីគុណសម្បត្តិនៃការ បំផុសគំនិត, ការពិភាក្សាជាក្រុម និងការសំដែងតួ ? (៥ពិន្ទុ)

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៦. ជំនាញសំខាន់ៗ ដែលអ្នកសំរបសំរួលដែលត្រូវមាន (៥ពិន្ទុ) :

☐ ជំនាញក្នុងការសួរសំនួរ និងស្តាប់

☐ ជំនាញធ្វើការបង្ហាញ

☐ ជំនាញក្នុងការប្រាស្រ័យទំនាក់ទំនង

☐ ចំលើយទាំងអស់ខាងលើ

៧. ចូររៀបរាប់អំពីការរៀបចំកៅអីសំរាប់ការប្រជុំ/សិក្ខាសាលា អោយបាន ៥របៀបផ្សេងគ្នា? ព្រមទាំងបញ្ជាក់ពីគុណសម្បត្តិ និងគុណវិបត្តនៃរបៀបនីមួយៗ? (១៥ពិន្ទុ)

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

៨. តើអ្វីខ្លះដែលជាការខុសប្លែកគ្នារវាងការរៀនរបស់កុមារ និងការរៀនរបស់មនុស្សចាស់? (១០ពិន្ទុ)

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

៩. តើអ្វីទៅជាគំរោងមេរៀន? តើចំនុចសំខាន់ៗអ្វីខ្លះ ដែលត្រូវបញ្ចូលនៅក្នុងការរៀបចំគំរោងមេរៀន? (១៥ពិន្ទុ)

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

១០. តើនៅក្នុងវគ្គបណ្តុះបណ្តាលមួយ អាចមានការវាយតំលៃប៉ុន្មានប្រភេទ? ចូរពន្យល់ពីភាពខុសគ្នា នៃការវាយតំលៃនីមួយៗទាំងនោះ? (១៥ ពិន្ទុ)

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

....................................................................................................................................................... ។

**សូមអរគុណ ចំពោះការប្រឹងប្រែងរបស់លោក-អ្នក !!!**

## ខ. តារាងវាយតំលៃប្រចាំថ្ងៃ វគ្គបណ្តុះបណ្តាលស្តីពីជំនាញសំរបសំរួល

## ថ្ងៃទី............ខែ............ឆ្នាំ..............

១. តើអ្នកបានសិក្សាពីប្រធានបទអ្វីខ្លះសំរាប់ថ្ងៃនេះ? ..........................................................................................

.......................................................................................................................................................

.......................................................................................................................................................

២. ក្នុងចំណោមប្រធានបទទាំងអស់នោះ តើអ្នកយល់ថាមានប្រធានបទដែលមានសារៈសំខាន់បំផុតសំរាប់អ្នកដែរ រឺទេ ? បើមាន តើប្រធានបទអ្វី?.........................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

៣. តើអ្នកយល់យ៉ាងដូចម្តេចចំពោះការសំរបសំរួលវគ្គថ្ងៃនេះ? (យឺតពេក, លឿនពេក, ល្មមសមរម្យ, រឺយ៉ាងដូចម្តេច )

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

៤. តើអ្នកមានមើលឃើញចំនុចខ្វះខាតអ្វីខ្លះក្នុងការសំរបសំរួលរបស់អ្នកសំរបសំរួល នៅថ្ងៃនេះ? សូមផ្តល់នូវអនុសាសន៏កែលំអ សំរាប់ការសំរបសំរួលនៅថ្ងៃបន្ទាប់ទៀត ?..............................................................................................

.......................................................................................................................................................

.......................................................................................................................................................

.............................................................................................................................................................................

៥. តើអ្នកមានសំណូមពរអ្វីបន្ថែមទៀត....................................................................................................................

.............................................................................................................................................................................

.............................................................................................................................................................................

.............................................................................................................................................................................

**សូមអរគុណ ចំពោះការកែលំអរបស់លោក-អ្នក !!!**

## គ. ការវាយតំលៃបញ្ចប់វគ្គបណ្តុះបណ្តាល

| ល.រ | ប្រធានបទ | ការវាយតំលៃរបស់សិក្ខាកាម | | | អនុសាសន៍កែលំអ |
|---|---|---|---|---|---|
| | | ☺ | 😐 | ☹ | |
| ១ | ប្រធានបទសំរាប់វគ្គ | | | | |
| ២ | ការរៀបចំឯកសារ | | | | |
| ៣ | រយះពេលសំរាប់វគ្គបណ្តុះបណ្តាល | | | | |
| ៤ | វិធីសាស្រ្តសំរបសំរួលរបស់គ្រូបណ្តុះបណ្តាល | | | | |
| ៥ | បរិយាកាសរបស់វគ្គបណ្តុះបណ្តាល | | | | |
| ៦ | **ការវាយតំលៃ និងអោយអនុសាសន៍រួមសំរាប់វគ្គបណ្តុះបណ្តាលទាំងមូល :** ..................................................<br>..........................................................................................................................<br>..........................................................................................................................<br>.......................................................................................................................... | | | | |

**សូមអរគុណ ចំពោះការកែលំអរបស់លោក-អ្នក !!!**

# ឃ. ទំរង់បែបបទសំរាប់វាយតំលៃ
# អំពីប្រសិទ្ធិភាពនៃវគ្គបណ្តុះបណ្តាល
# របស់អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍

-----------------------------------

ដោយបានចាប់ផ្តើមវគ្គបណ្តុះបណ្តាលនៅខែមីនា ឆ្នាំ២០០៦ រហូតមកដល់បច្ចុប្បន្ន អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ បានបើកវគ្គបណ្តុះបណ្តាល សិក្ខាសាលាសរុបចំនួន៨វគ្គហើយដល់និស្សិត បុគ្គលិកអង្គការ-ស្ថាប័ននានា សរុបចំនួនជាង២០០នាក់ ក្នុងគោលដៅចូលរួមចំណែកពង្រឹងសមត្ថភាពដល់បណ្ឌិនិស្សិត អង្គការ-ស្ថាប័ននានាអោយមានលទ្ធភាពងាយស្រួល អាចចាប់ផ្តើម និងអភិវឌ្ឍន៍អាជីពការងារបានប្រកបដោយប្រសិទ្ធិភាព ដែលបង្កឱកាសអាចអោយបុគ្គលទាំងនោះបានរួមចំណែកដល់ការអភិវឌ្ឍន៍សហគមន៍ និងសង្គមជាតិ។

ក្នុងគោលបំណងដើម្បីស្វែងយល់អំពីប្រសិទ្ធិភាពនៃវគ្គបណ្តុះបណ្តាលដែលរៀបចំឡើងដោយអង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍កន្លងមក ក៏ដូចជាស្វែងរកអោយមានការកែលំអ និងចូលរួមចំណែកអោយកាន់តែមានប្រសិទ្ធិភាពនៅក្នុងការអភិវឌ្ឍន៍ចំណេះដឹង បទពិសោធន៍សំរាប់បុគ្គល សហគមន៍ និងសង្គមជាតិទាំងមូលតាមរយៈការបង្កើតវគ្គបណ្តុះបណ្តាល សិក្ខាសាលា អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ សូមអនុញ្ញាតិលោក លោកស្រី កញ្ញា ជាអតីតសិក្ខាកាមនៅក្នុងវគ្គបណ្តុះបណ្តាលដែលរៀបចំឡើងដោយអង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ មេត្តាចូលរួមផ្តល់នូវយោបល់ស្តីអំពីការប្រើប្រាស់ចំណេះដឹងរបស់ខ្លួន ក៏ដូចជាការកែលំអនានា ដោយឆ្លើយនូវសំណួរទាំងអស់ដូចខាងក្រោមនេះដោយអនុគ្រោះ

**ឈ្មោះអ្នកផ្តល់ពត៌មាន...................................ភេទ.........ថ្ងៃខែឆ្នាំកំណើត........................**

**ទីកន្លែងកំណើត (ភូមិ ឃុំ ស្រុក ខេត្ត)........................................................................**

**ទីកន្លែងស្នាក់នៅបច្ចុប្បន្ន............................................................................................**

**ទូរស័ព្ទ..........................................អ៊ីម៉ែល.........................................................**

១. តើអ្នកធ្លាប់បានចូលរៀនវគ្គបណ្តុះបណ្តាលអ្វីខ្លះនៅអង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍

ក. ឈ្មោះវគ្គ................................................................, កាលបរិច្ឆេទវគ្គ..............................................

ខ. ឈ្មោះវគ្គ................................................................, កាលបរិច្ឆេទវគ្គ..............................................

គ. ឈ្មោះវគ្គ................................................................, កាលបរិច្ឆេទវគ្គ..............................................

ឃ. ឈ្មោះវគ្គ................................................................, កាលបរិច្ឆេទវគ្គ..............................................

២. តើនៅមុនពេលដែលអ្នកចូលរួមវគ្គបណ្តុះបណ្តាលនៅអង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ តើមុខរបរអ្នកជា អ្វី?នៅឯណា?

☐ ជានិស្សិត, បើជានិស្សិត តើពេលនោះសិក្សានៅឆ្នាំទីប៉ុន្មាន?...........សាកលវិទ្យាល័យណា?...............................

ជំនាញអ្វី?...........................................................................................................................................

☐ ជាបុគ្គលិក, បើជាបុគ្គលិក តើពេលនោះធ្វើការក្នុងតំណែងអ្វី?...........................................................................

នៅអង្គការ រឺស្ថាប័នណា?.......................................................................................................................

៣. តើសព្វថ្ងៃនេះ អ្នកមានមុខរបរជាអ្វី?នៅឯណា?

☐ ជានិស្សិត, បើជានិស្សិត តើពេលនោះសិក្សានៅឆ្នាំទីប៉ុន្មាន?...........សាកលវិទ្យាល័យណា?...............................

ជំនាញអ្វី?...........................................................................................................................................

☐ ជាបុគ្គលិក, បើជាបុគ្គលិក តើពេលនេះធ្វើការក្នុងតំណែងអ្វី?...........................................................................

នៅអង្គការ រឺស្ថាប័នណា?.......................................................................................................................

៤. តើអ្នកគិតថា ចំណេះដឹងដែលទទួលបានពីវគ្គបណ្តុះបណ្តាលនៅអង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ បានចូលរួម ចំណែកនៅក្នុងការសិក្សា រឺការបំពេញការងាររបស់អ្នកដែររឺទេ?.......................................................

ព្រោះអ្វី?...........................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

៥. តើអ្នកធ្លាប់បានយកចំណេះដឹង បទពិសោធន៍ដែលទទួលបានពីវគ្គបណ្តុះបណ្តាលនៅអង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ ទៅប្រើប្រាស់ដែររឺទេ?

☐ មិនបានយកទៅប្រើប្រាស់ឡើយ, ហេតុអ្វី?.................................................................................................

☐ ប្រើប្រាស់, បើប្រើប្រាស់, តើប្រើប្រាស់ដើម្បីអ្វី?

☐ ការសិក្សានៅសាកលវិទ្យាល័យ, ☐ ការស្វែងរកការងារ

☐ ការអភិវឌ្ឍន៍ការងារថ្មី ☐ កែលំអប្រសិទ្ធិភាពធ្វើការងារនៅទីកន្លែងធ្វើការ

- នៅក្រោយពីចូលរៀនវគ្គបណ្តុះបណ្តាលនៅអង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ តើអ្នកធ្លាប់បានស្វែងរកការងារ ថ្មីដែររឺទេ? ☐ ធ្លាប់, ☐ មិនធ្លាប់

- បើធ្លាប់ស្វែងរកការងារថ្មី, តើអ្នកទទួលបានជោគជ័យនៅក្នុងការស្វែងរកការងារថ្មីនោះរឺទេ? ☐ មិនជោគជ័យ

☐ ជោគជ័យ, បើជោគជ័យ តើអ្នកគិតថាចំណេះដឹងដែលទទួលបានពីវគ្គបណ្តុះបណ្តាលនៅអង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ បានចូលរួមចំណែកធ្វើអោយមានភាពជោគជ័យរបស់អ្នកដែររឺទេ?...........................................

ព្រោះអ្វី?...........................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៦. តើនៅក្រៅពីការចូលរួមវគ្គបណ្តុះបណ្តាលនៅអង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ រហូតមកដល់ពេលបច្ចុប្បន្ននេះ អ្នកធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលជាមួយអង្គការ-ស្ថាប័នដទៃទៀតដែរឬទេ?..................................

ក.ឈ្មោះវគ្គ............................................................, កាលបរិច្ឆេទវគ្គ................, ស្ថាប័ន.........................

ខ. ឈ្មោះវគ្គ............................................................, កាលបរិច្ឆេទវគ្គ................, ស្ថាប័ន.........................

គ. ឈ្មោះវគ្គ............................................................, កាលបរិច្ឆេទវគ្គ................, ស្ថាប័ន.........................

ឃ. ឈ្មោះវគ្គ............................................................, កាលបរិច្ឆេទវគ................, ស្ថាប័ន.........................

ង. ឈ្មោះវគ្គ............................................................, កាលបរិច្ឆេទវគ្គ................, ស្ថាប័ន.........................

៧. តើអ្នកគិតថា មានវគ្គបណ្តុះបណ្តាលអ្វីទៀត ដែលអ្នកចង់ចូលរួមបន្ថែមទៀត?

ក. ឈ្មោះវគ្គ.......................................................................................................................................

ខ. ឈ្មោះវគ្គ.......................................................................................................................................

គ. ឈ្មោះវគ្គ.......................................................................................................................................

៨. តើអ្នកគិតថា វគ្គបណ្តុះបណ្តាលដែលរៀបចំឡើងដោយអង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ មានចំនុចខ្សោយ រឺចំនុចខ្វះខាតអ្វីខ្លះ?

☐ ការសំរបសំរួលរបស់អ្នកសំរបសំរួល, ពន្យល់លំអិត:.............................................................................

☐ ការរៀបចំឯកសារមេរៀន, ពន្យល់លំអិត:.........................................................................................

☐ បរិយាកាសក្នុងពេលបណ្តុះបណ្តាល, ពន្យល់លំអិត:...........................................................................

☐ រយៈពេលសំរាប់វគ្គបណ្តុះបណ្តាល ពន្យល់លំអិត:...........................................................................

☐ ផ្សេងៗ.........................................................................................................................................

៩. តើអ្នកមានយោបល់អ្វីខ្លះ ដើម្បីកែលំអ និងបង្កើនប្រសិទ្ធិភាពនៃវគ្គបណ្តុះបណ្តាលដែលរៀបចំឡើងដោយអង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍?.............................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

**សូមអរគុណជាអនេកដល់ការចំណាយពេលវេលា និងផ្តល់មតិកែលំអដល់យើងខ្ញុំ!!!**

## ឯកសារយោង


១. វគ្គជំនាញសំរបសំរួល, អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍, ខែកញ្ញា ២០០៦

២. គន្លឹះសំរាប់គ្រូបណ្តុះបណ្តាល, LWF

៣. របៀបធ្វើជាគ្រូបង្គោលតាមអង្គការ, រៀបរៀងដោយ លោក ឈួន បូរិត ប្រធានអង្គការ KYSD